# អង្គការសហប្រជាជាតិ

# មហាសន្និបាត

ក្រុមប្រឹក្សាសិទ្ធិមនុស្ស

សម័យប្រជុំលើកទី១៥

របៀបវារៈទី១០

ជំនួយការបច្ចេកទេសនិងការកសាងសមត្ថភាព

## របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា លោកសាស្ត្រាចារ្យ សូរិយា ប្រាសាដ ស៊ូបេឌី

## សង្ខេបសេចក្តី

ប្រទេសកម្ពុជា បានរីកចំរើនគួរឲ្យកត់សំគាល់ក្នុងវិស័យការពារ និងលើកស្ទួយសិទ្ធិមនុស្ស រួមបញ្ចូលទាំងការអនុម័តច្បាប់ចម្បងៗមួយចំនួនទាក់ទិននឹងវិស័យនេះ។ រាជរដ្ឋាភិបាល បានសហការកាន់តែជិតស្និតឡើងជាមួយនឹងស្ថាប័នទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិនានា ហើយបានទទួលយកអនុសាសន៍ទាំងអស់ ដែលបានផ្តល់ឲ្យនៅកំឡុងការពិនិត្យឡើងវិញជាសកលតាមកាលកំណត់-UPR កាលពីខែធ្នូ ឆ្នាំ២០០៩ ដែលបានរួមបញ្ចូលនូវការពង្រឹងឯករាជភាព និងសមត្ថភាពតុលាការ។ នៅក្នុងគំនិតរបស់អ្នករាយការណ៍ពិសេសេ កម្ពុជានៅតែជាប្រទេសដែលមានភាពស្មុគស្មាញនៅឡើយ ទាក់ទិននឹងវិស័យការពារ និងលើកស្ទួយសិទ្ធិមនុស្ស ដោយសារតែលទ្ធិប្រជាធិបតេយ្យ ពុំទាន់ចាក់ឫសជ្រៅនៅក្នុងសង្គមនេះនៅឡើយ។ ការរំលោភសិទ្ធិមនុស្ស នៅតែបន្តកើតមាន នៅក្នុងវិស័យមួយចំនួន។ វិស័យជាកង្វល់ចម្បងៗ មានដូចជា វិវាទដីធ្លី និងសិទ្ធិលំនៅដ្ឋាន សេរីភាពនៃការបញ្ចេញមតិ និងបញ្ហាប្រឈមមួយចំនួនរបស់តុលាការ។ បញ្ហាទាំងនេះ នៅតែបន្តគ្របដណ្តប់លើបរិយាកាសគតិយុត្ត និងនយោបាយ។ អ្នករាយការណ៍ពិសេស ក៏មានកង្វល់ផងដែរ អំពីភាពចង្អៀតនៃបរិយាកាសនយោបាយ។ រាជរដ្ឋាភិបាល ត្រូវតែមានភាពអនុគ្រោះថែមទៀតចំពោះអ្នកពាក់ព័ន្ធក្នុងប្រទេស ក៏ដូចជាសហគមន៍អន្តរជាតិនៅក្នុងការជំរុញប្រទេសឆ្ពោះទៅមុខ។ អ្នករាយការណ៍ពិសេស ស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែង និងឆន្ទៈរបស់រាជរដ្ឋាភិបាល ក្នុងការបន្តធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្ស ព្រមទាំងពង្រឹងនូវឯករាជភាព និងសមត្ថភាពរបស់វិស័យតុលាការ។ គាត់ត្រូវបានលើកទឹកចិត្ត ដោយភាពបើកចំហនៃដៃគូសន្ទនាខាងរាជរដ្ឋាភិបាល ដែលចូលរួមក្នុងកិច្ចពិភាក្សាសំខាន់ៗ ដោយបានថ្លែងថា បញ្ហាទាំងឡាយ ត្រូវបានលើកឡើងនៅក្នុងលក្ខណៈអព្យាក្រឹត និងមិនប្រកាន់បក្សពួក ជាមួយនឹងចេតនាស្វែងរកដំណោះស្រាយនានា។ ស្ថិតក្នុងស្មារតីនេះ ដែលអ្នករាយការណ៍ពិសេស បានដាក់ចេញនូវអនុសាសន៍នានា នៅក្នុងរបាយការណ៍នេះ ហើយលើកទឹកចិត្តរាជរដ្ឋាភិបាល ឲ្យទទួលយកអនុសាសន៍ទាំងនេះ ទៅធ្វើការពិចារណា ព្រមទាំងដាក់បញ្ចូលទៅក្នុងកម្មវិធីសកម្មភាព ជាមួយនឹងកាលវិភាគច្បាស់លាស់ក្នុងការអនុវត្តន៍អនុសាសន៍ទាំងនេះ។

# មាតិកា


| | កថាខ័ណ្ឌ | ទំព័រ |
|---|---|---|
| ១. សេចក្តីផ្តើម | ១-៨ | ៣ |
| ២. វិធីសាស្ត្រ និងទស្សនៈវិស័យការងារ | ៩-១១ | 4 |
| ៣. ភាពរីកចំរើនថ្មីៗនៅក្នុងវិស័យសិទ្ធិមនុស្ស និងនីតិរដ្ឋ | 12-18 | 4 |
| ៤. ឯករាជភាព និងសមត្ថភាពនៃប្រព័ន្ធតុលាការ នៅកម្ពុជា | 19-29 | 6 |
| ក. ប្រព័ន្ធតុលាការបច្ចុប្បន្ន | ១៩ | 6 |
| ខ. ក្របខណ្ឌច្បាប់ សម្រាប់ឯករាជភាពនៃវិស័យតុលាការ | 20-22 | 6 |
| គ. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | 23-29 | 7 |
| ៥. បញ្ហានានានៅក្នុងនីតិវិធីច្បាប់ | 30-39 | 8 |
| ក. សិទ្ធិលំនៅដ្ឋាន និងសិទ្ធិទាក់ទងនឹងដីធ្លី | 31-32 | 8 |
| ខ. សេរីភាពនៃការបញ្ចេញមតិ | 33-36 | 9 |
| ៦. បញ្ហាប្រឈមចម្បងៗ សម្រាប់តុលាការ | 40-63 | 11 |
| សាលាជម្រះក្តីវិសាមញ្ញនៅក្នុងតុលាការកម្ពុជា | 58-63 | 14 |
| ៧. សេចក្តីសន្និដ្ឋាន | 64-65 | 15 |
| ៨. អនុសាសន៍ | 66-102 | 16 |

## ១. សេចក្តីផ្តើម

១. របាយការណ៍នេះ ត្រូវបានដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស ដោយអនុលោមតាមសេចក្តីសម្រេច ១២/២៥ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ នៃក្រុមប្រឹក្សាសិទ្ធិមនុស្ស។ អ្នករាយការណ៍ពិសេស បានបំពេញបេសកកម្មពីរលើកមកកាន់ប្រទេសកម្ពុជា នៅក្នុងឆ្នាំ២០១០ ចាប់ពីថ្ងៃទី១៧ ដល់៣០ ខែមករា និងចាប់ពីថ្ងៃទី៨ ដល់១៨ ខែមិថុនា។ អ្នករាយការណ៍ពិសេស សូមសំដែងនូវការដឹងគុណចំពោះរាជរដ្ឋាភិបាល ដែលបានផ្តល់កិច្ចសហប្រតិបត្តិការរបស់ខ្លួន នៅកំឡុងពេលនៃបេសកកម្មរបស់គាត់ ហើយដែលបានបង្ហាញនូវឆន្ទៈ ចង់ធ្វើការជាមួយគ្នា ប្រកបដោយការស្ថាបនា។

២. បន្ទាប់ពីបេសកកម្មលើកទីមួយរបស់គាត់ អ្នករាយការណ៍ពិសេសបានស្នើថា គាត់សូមពិនិត្យទៅលើការងារ និងប្រសិទ្ធភាពរបស់ស្ថាប័នរដ្ឋនានា ដែលទទួលបន្ទុកលើកស្ទួយ និងការពារសិទ្ធិមនុស្ស ហើយរាជរដ្ឋាភិបាលបានឯកភាព។ អ្នករាយការណ៍ពិសេស ជាបឋមបានចាប់ផ្តើមពិនិត្យទៅលើស្ថាប័នតុលាការ និងសមត្ថភាពរបស់ស្ថាប័ននេះ ក្នុងការស្វែងរកយុត្តិធម៌ ក៏ដូចជាការគោរព ទំនុកចិត្ត និងភាពជឿជាក់របស់ប្រជាពលរដ្ឋ។ ឆ្លើយតបទៅនឹងប្រធានបទទាំងប៉ុន្មាននេះ ទើបរបាយការណ៍នេះ ផ្តោតការយកចិត្តទុកដាក់ទាំងស្រុងទៅលើស្ថាប័នតុលាការ ព្រមទាំងផ្តល់អនុសាសន៍នានា ដើម្បីធ្វើឲ្យប្រសើរឡើងនូវឧត្តមភាព សមត្ថភាព និងឯករាជភាពរបស់ស្ថាប័ននេះ។

៣. អ្នករាយការណ៍ពិសេសសូមធ្វើសេចក្តីថ្លែងការណ៍ជាកិច្ចចាប់ផ្តើមថាអ្នកដឹកនាំនយោបាយរបស់កម្ពុជា បាននាំមកនូវស្ថេរភាពនយោបាយដែលចាំបាច់សម្រាប់ប្រទេស ក៏ដូចជា ការអភិវឌ្ឍន៍សេដ្ឋកិច្ចគួរឲ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ។ ប្រទេសកម្ពុជា ក៏បានរីកចំរើនផងដែរក្នុងការលើកស្ទួយប្រព័ន្ធយុត្តិធម៌ ព្រមទាំងធ្វើឲ្យប្រសើរឡើង ទាំងឯករាជភាព និងសមត្ថភាពនៃស្ថាប័នតុលាការ។ អ្នករាយការណ៍ពិសេស យល់ដឹងយ៉ាងច្បាស់អំពីការប្រឈមនានារបស់ស្ថាប័ននេះ ក្នុងការកសាងខ្លួនឯងឡើងវិញ បន្ទាប់ពីអតីតកាលដ៏សោកនាដកម្មរបស់ប្រទេសនេះ ដែលបានទទួលរងនូវការបំផ្លាញស្ទើរតែទាំងស្រុង។ បន្ទាប់ពីបានចាប់ផ្តើមធ្វើការ នៅក្នុងប្រទេសកម្ពុជា អ្នករាយការណ៍ពិសេស ក៏សូមស្វាគមន៍ផងដែរ ចំពោះការអនុម័តច្បាប់សំខាន់ៗនានា ដែលក្នុងនោះរួមមាន ក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីបាតុកម្ម និងច្បាប់ប្រឆាំងអំពើពុករលួយដែលត្រូវបានតាក់តែងឡើងដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌។

៤. អ្នករាយការណ៍ពិសេស បានយល់ដឹងអំពីកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ហើយបានបង្ហាញនូវការពេញចិត្តចំពោះការរីកចំរើនមួយចំនួន ដែលសម្រេចបានក្នុងវិស័យនេះ។ គាត់កោតសរសើរចំពោះការដែលរាជរដ្ឋាភិបាល បង្កើនខ្ទង់ថវិកាដល់ស្ថាប័នអយ្យការ។ អ្នករាយការណ៍ពិសេស មានសេចក្តីពេញចិត្តចំពោះការដែលរាជរដ្ឋាភិបាលស្វាគមន៍គំនិតរបស់គាត់ ហើយមានឆន្ទៈចង់ធ្វើការជាមួយមនុស្ស ព្រមទាំងស្ថាប័ននានា ដែលសហការក្នុងន័យស្ថាបនា។ រាជរដ្ឋាភិបាល បានទទួលយកនូវសំណើមួយចំនួនរបស់អ្នករាយការណ៍ពិសេស រួមបញ្ចូលទាំងការពង្រឹងក្របខណ្ឌគតិយុត្ត ទាក់ទិននឹងការបណ្តេញចេញ និងការតាំងទីលំនៅថ្មី ធ្វើឲ្យដំណើរការតាក់តែងច្បាប់កាន់តែមានតម្លាភាព ដោយធ្វើការចែករំលែកសេចក្តីព្រៀងច្បាប់ ដែលមានការប៉ះពាល់

ដល់បញ្ហាសិទ្ធិមនុស្សនានាជាមួយនឹងសហគមន៍ឲ្យបានទូលំទូលាយនិងស្វែងរកដំណោះស្រាយសម្រាប់យន្តការរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលមួយ ដើម្បីជំរុញដល់បរិយាកាសសហប្រតិបត្តិការ ក្នុងការពង្រឹងដល់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ អ្នករាយការណ៍ពិសេសមានសង្ឃឹមថា ស្មារតីនៃកិច្ចសហប្រតិបត្តិការ និងកិច្ចសន្ទនាប្រកបដោយផ្លែផ្កាជាមួយរាជរដ្ឋាភិបាលនេះ នឹងដំណើរការទៅមុខបន្តទៀត។

៥. កំឡុងពេលបេសកកម្មលើកទីមួយរបស់គាត់កាលពីខែមករា ឆ្នាំ២០១០ អ្នករាយការណ៍ពិសេសបានទទួលនូវឯកសិទ្ធិចូលជួបប្រជុំជាមួយនឹងសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ហើយសម្រេចបាននូវការយោគយល់គ្នាលើវិស័យសំខាន់ៗនានា សម្រាប់ការងារនាពេលអនាគតរបស់អ្នករាយការណ៍ពិសេស។ អ្នករាយការណ៍ពិសេស ពុំបានជួបប្រជុំជាមួយនឹងសម្តេចនាយករដ្ឋមន្ត្រី នៅកំឡុងបេសកកម្មរបស់គាត់កាលពីខែមិថុនា ឆ្នាំ២០១០ ដោយសារតែសម្តេចមានជម្ងឺនាពេលនោះ ហើយអ្នករាយការណ៍ពិសេស ក៏បានសរសេរលិខិតសួរសុខទុក្ខ ដល់សម្តេចផងដែរ។

៦. អ្នករាយការណ៍ពិសេស បានទទួលឯកសិទ្ធិចូលគាល់ព្រះបាទនរោត្តម សីហមុនី កំឡុងពេលនៃបេសកកម្មលើកទីបីរបស់គាត់។ កំឡុងពេលនៃបេសកកម្មទាំងពីរលើករបស់គាត់ នៅក្នុងឆ្នាំ២០១០ អ្នករាយការណ៍ពិសេស បានមានឱកាសចូលជួបប្រជុំជាមួយមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាល សមាជិករដ្ឋសភាជាតិ និងតុលាការ តំណាងសង្គមស៊ីវិលនានា ក៏ដូចជាក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា មន្ត្រីការទូត ដែលដាក់ទូតនៅក្នុងប្រទេសនេះ ព្រមទាំងជួបជាឯកជនជាមួយនឹងឯកត្តបុគ្គលនានាផងដែរ។

៧. កំឡុងពេលនៃបេសកកម្មរបស់គាត់ អ្នករាយការណ៍ពិសេស កំណត់បាននូវភាពអន់ថយមួយចំនួន នៅក្នុងដំណើរការប្រព្រឹត្តទៅនៃតុលាការ ហើយបានផ្តល់នូវអនុសាសន៍នានា ដើម្បីដោះស្រាយជាមួយនឹងបញ្ហាទាំងនោះ នៅផ្នែកសរុបសេចក្តីនៃរបាយការណ៍នេះ។ តាមគំនិតរបស់ខ្ញុំ ជនទីទាល់ក្រ ជនទន់ខ្សោយ និងជនភាគតិច រួមបញ្ចូលទាំងអស់អ្នកដែលពាក់ព័ន្ធនឹងវិវាទដីធ្លី ហាក់ដូចជាប្រឈមនឹងការលំបាកខ្លាំងណាស់ ក្នុងការទទួលបានយុត្តិធម៌ពីស្ថាប័នតុលាការ ហើយហាក់ដូចជាខំស្វះស្វែងរកជំនួយ នៅគ្រប់ច្រកល្ហកទាំងអស់ដែលពួកគេគិតថា អាចធ្វើទៅបាន រួមទាំង ទៅនៅមុខរបងផ្ទះរបស់សម្តេចនាយករដ្ឋមន្ត្រីផងដែរ។ ពួកគេភាគច្រើន ហាក់ដូចជាអន្ទះសារចង់បានយុត្តិធម៌យ៉ាងខ្លាំង ហើយសូម្បីតែធ្វើដំណើរទៅជួបអ្នករាយការណ៍ពិសេស នៅកំឡុងនៃការស្នាក់នៅរបស់គាត់ផងដែរ។

៨. ស្ថានភាពសិទ្ធិមនុស្សនៅប្រទេសកម្ពុជា គឺជាកម្មវត្ថុនៃការវិភាគដ៏លាតសន្ធឹង របស់អ្នកទទួលអណត្តិបន្តប្រចាំប្រទេសនេះ តាំងពីឆ្នាំ១៩៩៣មកម្ល៉េះ ជាពិសេសនៅក្នុងវិស័យតុលាការ។ របាយការណ៍នេះបន្តកសាងលើការងារកន្លងមករបស់ពួកគេ។ ទោះជាប្រទេសកម្ពុជា ជាសង្គមសម្លឹងមើលទៅមុខ ដែលបានធ្វើការតស៊ូដ៏ខ្លាំងក្លា ក្នុងការពង្រឹងសិទ្ធិមនុស្សនាប៉ុន្មានឆ្នាំថ្មីៗនេះ ក៏ប្រទេសនេះ នៅតែប្រឈមឧបសគ្គមួយចំនួន ដូចជាឧបសគ្គទាក់ទិននឹងសមត្ថភាព កង្វះហិរញ្ញវត្ថុ ឆន្ទៈនយោបាយ ព្រមទាំងប្រសិទ្ធភាពនៃស្ថាប័នរដ្ឋនានា នៅក្នុងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្ស។ ជាពិសេស គឺវិស័យតុលាការតែម្តង ដែលឯករាជភាពរបស់

ស្ថាប័ននេះ គឺជាកក្តាចម្បង ដែលជួយឲ្យប្រជាពលរដ្ឋអាចរីករាយជាមួយនឹងសិទ្ធិរបស់ពួកគេ។ វាគឺជាវិស័យមួយ ដែលមិនទាន់មានដំណោះស្រាយដ៏ជោគជ័យនៅឡើយ។

## ២. វិធីសាស្ត្រ និងទស្សនៈវិស័យការងារ

៩. អ្នករាយការណ៍ពិសេស និងរាជរដ្ឋាភិបាល បានឯកភាពគ្នា ធ្វើការពិនិត្យទៅលើការប្រព្រឹត្តទៅ និងប្រសិទ្ធភាពនៃស្ថាប័នរដ្ឋនានា ដែលទទួលបន្ទុកសម្រាប់ការលើកស្ទួយ និងការការពារនីតិរដ្ឋ ហើយនិង ដោះស្រាយបញ្ហាសិទ្ធិមនុស្សនានា រួមមានរដ្ឋសភា តុលាការ ក្រុមប្រឹក្សាធម្មនុញ្ញ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទីភ្នាក់ងារអនុវត្តច្បាប់ និងគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា។ គោល បំណងនៃការវាយតម្លៃនេះ គឺដើម្បីកំណត់នូវវិធី និងមធ្យោបាយនានា ក្នុងការពង្រឹងសមត្ថភាពរបស់ពួកគេ ឲ្យ គោរព និងការពារសិទ្ធិមនុស្ស។ អាស្រ័យដូច្នេះផងដែរ នៅកំឡុងពេលនៃបេសកកម្មរបស់គាត់កាលពីខែមិថុនា ឆ្នាំ២០១០ អ្នករាយការណ៍ពិសេសបានផ្តោតការងាររបស់គាត់ជាចម្បងទៅលើវិស័យតុលាការ។

១០. នៅកំឡុងពេលនៃទស្សនៈកិច្ចរបស់គាត់ អ្នករាយការណ៍ពិសេសបានជួបប្រជុំជាមួយប្រធាននិង សមាជិកផ្សេងៗទៀតនៃក្រុមប្រឹក្សាធម្មនុញ្ញ ប្រធានតុលាការកំពូល ប្រធានសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញាអម សាលាឧទ្ធរណ៍ ប្រធាន និងសមាជិកផ្សេងៗទៀតនៃគណៈមេធាវីកម្ពុជា មន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជា និងសមាជិកនានានៃស្ថាប័នតុលាការ។ គាត់ក៏បានជួបប្រជុំជាមួយនឹងជនរងគ្រោះនៃអំពើរំលោភសិទ្ធិមនុស្សផង ដែរ រួមមានក្រុមជនជាតិដើមភាគតិច និងសហគមន៍នានា ដែលទទួលផលប៉ះពាល់ដោយការបណ្តេញចេញ ពី ដីធ្លី នៅប៉ុន្មានឆ្នាំថ្មីៗនេះ ហើយបានសន្ទនាគ្នាជាមួយតំណាងសង្គមស៊ីវិលនានា ដែលធ្វើការក្នុងវិស័យកំណែ ទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ អ្នករាយការណ៍ពិសេស ក៏ទទួលបាននូវកិត្តិយសដ៏ឧត្តុងឧត្តមផងដែរ ដោយ ទទួលបានការអនុញ្ញាតឲ្យចូលបង្គំគាល់ព្រះមហាក្សត្រ នរោត្តម សីហមុនី។

១១. អ្នករាយការណ៍ពិសេស បានចុះទៅទស្សនៈកិច្ចតុលាការខេត្តកណ្តាល និងបានតាមដានសង្កេត មើលដំណើរការជំនុំជម្រះក្តីនៅតុលាការនោះផងដែរ។ លោកក៏បានចុះទស្សនៈកិច្ច ទៅសាលាឧទ្ធរណ៍ នៅ រាជធានីភ្នំពេញ និងតុលាការខេត្តបាត់ដំបង កំឡុងពេលនៃបេសកកម្មរបស់លោក កាលពីខែមករា ឆ្នាំ២០១០ និងបានសន្ទនាគ្នាជាមួយប្រធានតុលាការ និងអគ្គព្រះរាជអាជ្ញាផងដែរ។ នៅកំឡុងពេលនៃបេសកកម្មរបស់គាត់ កាលពីខែមិថុនា ឆ្នាំ២០១០ លោកបានចុះទស្សនៈកិច្ច ទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ECCC) និងបានសន្ទនាគ្នាជាមួយចៅក្រមជំនុំជម្រះ សហចៅក្រមស៊ើបសួរ សហព្រះរាជអាជ្ញា ព្រមទាំងមន្ត្រីជាន់ខ្ពស់ របស់តុលាការជាច្រើនរូបផ្សេងទៀត។ លោកក៏បានចុះទស្សនៈកិច្ចទៅកាន់មណ្ឌលឃុំខ្លួន ដែលឃុំឃាំងជនជាប់ ចោទទាំងប្រាំរូបរបស់ECCC ផងដែរ។

## ៣. ភាពរីកចំរើនថ្មីៗនៅក្នុងវិស័យសិទ្ធិមនុស្ស និងនីតិរដ្ឋ

១២. អ្នករាយការណ៍ពិសេស មានក្តីសោមនស្សនឹងរាយការណ៍អំពីការរីកចំរើនដែលសម្រេចបាន គួរ ឲ្យកត់សំគាល់នៅក្នុងវិស័យសិទ្ធិមនុស្ស និងនីតិរដ្ឋនៅក្នុងប្រទេសកម្ពុជាចាប់តាំងពីទស្សនៈកិច្ចលើកទីមួយរបស់

លោក កាលពីខែមករា ឆ្នាំ២០០៩ ដែលរួមមាន ការពង្រឹងក្របខណ្ឌច្បាប់ ក្នុងការរៀបចំបញ្ហា បណ្តេញប្រជាពលរដ្ឋទីក្រុងពីលំនៅដ្ឋាន និងការតាំងទីលំនៅថ្មី បញ្ហានៃការបញ្ចប់រឿងក្តីទីមួយ នៅអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ព្រមទាំងសាលក្រមរបស់ខ្លួន កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ក៏ដូចជាដំណើរការទៅយ៉ាងរលូននៃការស៊ើបសួរលើសំណុំរឿងបន្ទាប់ បន្តកិច្ចខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ប្រព័ន្ធពន្ធនាគារ ហើយនិងរបបធ្វើបាតុកម្មជាសាធារណៈ កាន់តែច្បាស់លាស់ជាងមុន។

១៣. រាជរដ្ឋាភិបាល បានពន្លឿនដំណើរការតាក់តែងច្បាប់នៅក្នុងវិស័យមួយចំនួន ដែលបង្កើតឡើងដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌នៅក្នុងប្រទេសកម្ពុជា។ ច្បាប់ចម្បងៗថ្មីបួន ដែលមានផលប៉ះពាល់ដោយផ្ទាល់ទៅលើសិទ្ធិមនុស្ស ត្រូវបានអនុម័តដោយរដ្ឋសភាជាតិកម្ពុជា កំឡុងពេលនៃការត្រួតពិនិត្យឡើងវិញ មានដូចជា ក្រមព្រហ្មទណ្ឌកាលពីខែតុលា ឆ្នាំ២០០៩ ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីកាលពីខែតុលា ឆ្នាំ២០០៩ ច្បាប់ស្តីពីអស្សាមិករណ៍ កាលពីខែកុម្ភៈ ឆ្នាំ២០១០ និងច្បាប់ប្រឆាំងអំពើពុករលួយ កាលពីខែមីនា ឆ្នាំ២០១០។

១៤. រាជរដ្ឋាភិបាល ក៏បានចេញសារាចរស្តីពីដំណោះស្រាយសម្រាប់ការតាំងទីលំនៅបណ្តោះអាសន្ននៅលើដីកាន់កាប់ដោយខុសច្បាប់ នៅក្នុងតំបន់ទីក្រុង និងទីប្រជុំជន កាលពីខែឧសភា ឆ្នាំ២០១០ ដើម្បីដោះស្រាយនឹងបញ្ហាស្មុគស្មាញនានា ដែលទាក់ទិននឹងការបណ្តេញចេញពីដីនៅទីក្រុង។ រួមគ្នាជាមួយនឹងច្បាប់ស្តីពីអស្សាមិករណ៍ សារាចរនេះ អាចត្រូវគេចាត់ទុកថាជាការចាប់ផ្តើម នៃដំណើរការអនុវត្តអនុសាសន៍របស់ស្ថាប័នសិទ្ធិមនុស្សនានារបស់សហប្រជាជាតិដើម្បីអនុម័តនូវសេចក្តីណែនាំថ្នាក់ជាតិនានាស្តីពីការបណ្តេញចេញ និងការតាំងទីលំនៅថ្មី។

១៥. ច្បាប់ទាំងនេះ ជាការរីកចំរើនគួរឲ្យស្វាគមន៍។ យ៉ាងណាមិញ អ្នករាយការណ៍ពិសេស សូមកត់សំគាល់នូវកង្វល់មួយចំនួន ក្នុងចំណោមអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានា ដោយសារតែពុំត្រូវបានផ្តល់ឱកាសគ្រប់គ្រាន់ ដើម្បីផ្តល់មតិយោបល់ទៅលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់មួយចំនួន ដែលបានរៀបរាប់ពីខាងលើ មុនពេលរដ្ឋសភាអនុម័តច្បាប់ទាំងនេះ។ ក៏មានការលើកឡើងនូវកង្វល់នានាផងដែរ ចំពោះអ្នករាយការណ៍ពិសេស អំពីឱកាសមិនគ្រប់គ្រាន់សម្រាប់សមាជិកសភា ជាពិសេសសមាជិកសភាមកពីគណៈបក្សប្រឆាំងនានា ក្នុងការជជែកដេញដោលឲ្យអស់ប្រសិទ្ធភាព ហើយធ្វើការកែប្រែសេចក្តីព្រាងច្បាប់ទាំងនោះ តាមតែអាចធ្វើទៅបាន មុនពេលដែលរដ្ឋសភាអនុម័ត។

១៦. ប្រទេសកម្ពុជា បានឆ្លងកាត់ការពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (UPR) ដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស កាលពីឆ្នាំ២០០៩ (A/HRC/13/4)។ ឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការបន្តធ្វើឲ្យ ប្រសើរឡើងនូវស្ថានភាពសិទ្ធិមនុស្ស និងពង្រឹងឯករាជភាពនៃស្ថាប័នតុលាការ ត្រូវបានស្តែងឡើង តាមរយៈការដែលរាជរដ្ឋាភិបាលទទួលយកអនុសាសន៍ទាំង៩១របស់UPR។ នេះគឺជាការរីកចំរើនដ៏គួរឲ្យស្វាគមន៍។ នៅក្នុងគំនិតរបស់អ្នករាយការណ៍ពិសេស ការទទួលយកនេះ បង្ហាញឲ្យឃើញនូវការប្តេជ្ញាជាសាធារណៈរបស់រាជរដ្ឋាភិបាល ដើម្បីបន្ត

កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការកសាងប្រព័ន្ធនីតិរដ្ឋ ដែលដំណើរការអនុលោមតាមនិយាមសិទ្ធិមនុស្សអន្តរជាតិ ដែលជាកត្តាសំខាន់មួយក្នុងការអភិវឌ្ឍន៍ប្រទេស។ អ្នករាយការណ៍ពិសេស បានចេញសេចក្តីថ្លែងការណ៍សារព័ត៌មានមួយ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០ ដោយធ្វើការស្វាគមន៍ចំពោះការសម្រេចចិត្តរបស់រដ្ឋាភិបាល និងលើកទឹកចិត្តឲ្យរដ្ឋាភិបាល ធ្វើការផ្សាភ្ជាប់នឹងអ្នកពាក់ព័ន្ធចម្បងៗ ដែលរួមមានអង្គការសង្គមស៊ីវិល ក្នុងការអនុវត្តនូវអនុសាសន៍នានា។

១៧. នៅកំឡុងបេសកកម្មរបស់លោក អ្នករាយការណ៍ពិសេសបានសង្កេតឃើញថា មាននៅសេសសល់កង្វះនៃកិច្ចសន្ទនាដ៏មានអត្ថន័យ និងទៀងទាត់រវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនានា សម្រាប់ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស។ អ្នករាយការណ៍ពិសេស បានចង្អុលបង្ហាញនូវអត្ថប្រយោជន៍នៃការធ្វើកិច្ចការជាមួយសង្គមស៊ីវិល នៅក្នុងកិច្ចប្រជុំរបស់លោក កាលពីខែមករា ឆ្នាំ២០១០ ជាមួយលោកនាយករដ្ឋមន្ត្រី ដែលបានស្វាគមន៍ទទួលនូវគំនិតដែលបានលើកឡើងនេះ។ អង្គការសង្គមស៊ីវិលនានា បានចាប់ផ្តើមពិភាក្សាគ្នាអំពីមធ្យោបាយល្អបំផុត ក្នុងការទទួលយកគំនិតមួយនេះ។ អ្នករាយការណ៍ពិសេស មានក្តីរំភើបយ៉ាងខ្លាំង ដោយបានឃើញថ្នាក់ដឹកនាំ សង្គមស៊ីវិលដែលតំណាងឲ្យអង្គការជាង៣០០ បានចូលរួមក្នុងកិច្ចពិភាក្សា ប្រកបដោយស្មារតីសហប្រតិបត្តិការ និងពុះកញ្ជ្រោល។ លោកសូមថ្លែងអំណរគុណសម្រាប់កិច្ចខិតខំរបស់ពួកគេ ក្នុងការតាក់តែងនូវសំណើរួមដ៏ច្បាស់លាស់មួយដាក់ជូនដល់លោក ហើយលោកមានគម្រោង នឹងបញ្ជូនសំណើនេះបន្តទៅដល់លោកនាយករដ្ឋមន្ត្រី ជាឯកសារការងារសម្រាប់ឲ្យលោកធ្វើការពិចារណា។

១៨. នៅកំឡុងនៃបេសកកម្មរបស់លោក អ្នករាយការណ៍ពិសេស ត្រូវបានរដ្ឋាភិបាលជំរុញឲ្យធ្វើការប្រាស្រ័យទាក់ទងជាមួយសហគមន៍អង្គការសង្គមស៊ីវិលឲ្យបានទូលំទូលាយជាងនេះ ដោយមិនគ្រាន់តែធ្វើការជាមួយក្រុមអង្គការ ដែលចូលចិត្តទិតៀនរដ្ឋាភិបាលនោះទេ។ អ្នករាយការណ៍ពិសេស បានថ្លែងថា លោកសូមស្វាគមន៍ចំពោះឱកាសបានធ្វើការជាមួយអង្គការសង្គមស៊ីវិល ដែលមកពីប្រភពផ្សេងគ្នា និងមានទស្សនវិស័យផ្សេងគ្នា លើសកម្មភាពរបស់មនុស្សឲ្យបានច្រើន តាមតែអាចធ្វើទៅបាន។ លោកបានសរសេរប្រាប់ទៅឯកឧត្តម ឱម យ៉ិនទៀង ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា(CHRC) កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ ដើម្បីសុំយោបល់ស្តីពីអង្គការសង្គមស៊ីវិល ឬក្រុមនានា ដែលរដ្ឋាភិបាលចង់បាន។ ជាជម្រើសមួយទៀត អ្នករាយការណ៍ពិសេស ក៏បានបង្ហាញនូវសុឆន្ទៈចង់ចូលរួមកិច្ចប្រជុំមួយ ដែលរៀបចំឡើងដោយ CHRC ជាមួយអង្គការទាំងនេះ ប្រសិនជាអាចធ្វើទៅបាន។ អ្នករាយការណ៍ពិសេស មានក្តីសោមនស្សចំពោះសំណើរបស់លោកប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្នុងការរៀបចំឲ្យមានជាសិក្ខាសាលាបណ្តុះបណ្តាលសម្រាប់ចៅក្រម និងព្រះរាជអាជ្ញានានា នៅកំឡុងបេសកកម្មបន្ទាប់របស់លោកមកកាន់ប្រទេសនេះ លើបញ្ហានានាដែលទាក់ទិននឹងវិស័យតុលាការ។ អ្នករាយការណ៍ពិសេស បានស្វាគមន៍ចំពោះឱកាសបែបនោះ។

## ៤. ឯករាជភាព និងសមត្ថភាពរបស់ប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា

### ក. ប្រព័ន្ធតុលាការបច្ចុប្បន្ន

១៩. ប្រព័ន្ធតុលាការកម្ពុជា មានសមាសភាពតុលាការកំពូលមួយ សាលាឧទ្ធរណ៍មួយ តុលាការខេត្តចំនួន១៩ តុលាការរាជធានីចំនួន២ និងតុលាការយោធាចំនួន១។ ខេត្តចំនួន៣ ពុំមានតុលាការនោះទេ ហើយរឿងក្តីដែលមកពីខេត្តទាំងនេះ ត្រូវបើកសវនាការជំនុំជម្រះដោយតុលាការខេត្តក្បែរខាងនានា។[1] សាលាឧទ្ធរណ៍មានចៅក្រមចំនួន១២រូប ស្ថិតនៅរាជធានីភ្នំពេញ បើកសវនាការជំនុំជម្រះគ្រប់រឿងក្តីទាំងអស់ ដែលត្រូវបានប្តឹងឧទ្ធរណ៍ពីតុលាការដំបូងនានា។ អង្គជំនុំជម្រះដែលមានចៅក្រមបីរូប បើកសវនាការជំនុំជម្រះឡើងវិញ លើបញ្ហាអង្គហេតុ និងអង្គច្បាប់ ហើយអាចបើកការស៊ើបសួរបន្ថែម។ តុលាការកំពូល មានសមាសភាពប្រធាន១រូប អនុប្រធាន១រូប និងចៅក្រមមួយចំនួន។ អង្គជំនុំជម្រះដែលមានចៅក្រម៥រូប បើកសវនាការជំនុំជម្រះបញ្ហាអង្គច្បាប់ចំពោះរឿងក្តីដែលត្រូវបានប្តឹងសាទុក្ខលើកទី១ពីសាលាឧទ្ធរណ៍ និងអង្គជំនុំជម្រះដែលមានចៅក្រម៩រូប បើកសវនាការជំនុំជម្រះលើបញ្ហាទាំងអង្គហេតុ និងអង្គច្បាប់ ក្នុងករណីដែលមានការប្តឹងសាទុក្ខលើកទី២ ក្រោយពេលដែលសាលាឧទ្ធរណ៍ ពុំបានសម្រេចតាមសាលដីកាបញ្ជូនរឿងឲ្យជំនុំជម្រះឡើងវិញរបស់តុលាការកំពូល។ តុលាការនេះ ក៏បើកសវនាការជំនុំជម្រះលើបណ្តឹងសើរើទូទៅផងដែរ ប្រឆាំងនឹងសាលក្រមស្ថាពរ ដោយសំអាងហេតុថា មានការរកឃើញភស្តុតាងថ្មីដែលបង្ហាញពីភាពគ្មានទោសរបស់ទណ្ឌិត ហើយដែលភស្តុតាងនោះ ពុំត្រូវបានលើកមកបង្ហាញនៅពេលជំនុំជម្រះនោះ។ ការតែងតាំងចៅក្រម ត្រូវធ្វើឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលក៏ជាស្ថាប័នមួយទទួលបន្ទុកដាក់វិន័យក្នុងវិជ្ជាជីវៈនេះផងដែរ។ ការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម ជាបន្ទុករបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការថ្មី ដែលមានសាលាចៅក្រម (រួមបញ្ចូលព្រះរាជអាជ្ញា[2]) និងសាលាក្រឡាបញ្ជី។ ទន្ទឹមនឹងនោះ ក៏មានសមាគមវិជ្ជាជីវៈមេធាវីផងដែរ ប៉ុន្តែពុំទាន់មានសមាគមចៅក្រមនៅឡើយ។

### ខ. ក្របខណ្ឌច្បាប់សម្រាប់ឯករាជភាពរបស់តុលាការ

#### រដ្ឋធម្មនុញ្ញ

២០. រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣នៃព្រះរាជាណាចក្រកម្ពុជា ចែងនៅក្នុងមាត្រា១២៨ថា អំណាចតុលាការជាអំណាចឯករាជ្យ ដែលធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។ មាត្រា១២៩ ចែងថាការជំរះក្តីផ្តល់យុត្តិធម៌ត្រូវធ្វើក្នុងនាមប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន។ មានតែចៅក្រមទេដែលមានសិទ្ធិជំរះក្តី ហើយត្រូវបំពេញភារកិច្ចនេះ ដោយគោរពច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន។ មាត្រា១៣០ ចែងថា គ្មានអង្គការណាមួយនៃអំណាចនីតិបញ្ញត្តិ ឬនីតិប្រតិបត្តិ អាចទទួលអំណាច

---

[1] សព្វថ្ងៃ កម្ពុជាមានតុលាការ២១ខេត្ត-ក្រុង។ តុលាការខេត្តពីរទៀតទើបតែបង្កើតថ្មីដោយផ្តាច់ចេញពីយុត្តាធិការតុលាការខេត្តបាត់ដំបងនិងខេត្តសៀមរាប គឺតុលាការខេត្តប៉ៃលិន និងតុលាការខេត្តឧត្តរមានជ័យ។ ជាសរុប កម្ពុជាមានតុលាការ២៣ខេត្ត-ក្រុង។ ខេត្តតែមួយគត់ ដែលស្ថិតនៅក្រោមយុត្តាធិការតុលាការខេត្តកំពត គឺខេត្តកែប។

[2] ដូចគ្នានឹងប្រព័ន្ធច្បាប់ស៊ីវិលរបស់ប្រទេសបារាំង ព្រះរាជអាជ្ញាមានឋានៈជាចៅក្រម (ចៅក្រមឈរ) នៅអមចៅក្រមអាសនៈ (ចៅក្រមអង្គុយ)។ សាលានេះ បណ្តុះបណ្តាលដល់ព្រះរាជអាជ្ញា និងចៅក្រម ទាំងតុលាការ រដ្ឋប្បវេណី និងព្រហ្មទណ្ឌ។

តុលាការអ្វីបានឡើយ ហើយមាត្រា១៣១ ចែងថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ មាត្រា១៣២ នៃរដ្ឋធម្មនុញ្ញ ផ្តល់ឲ្យព្រះមហាក្សត្រនូវតួនាទីជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ ហើយផ្តល់អាណត្តិដល់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។

**ច្បាប់ផ្សេងទៀត**

២១. រដ្ឋធម្មនុញ្ញតម្រូវថាលក្ខន្តិកៈនៃអង្គចៅក្រមនិងព្រះរាជអាជ្ញានឹងត្រូវកំណត់ក្នុងច្បាប់ដោយឡែកមួយ។ ច្បាប់នេះមិនទាន់ត្រូវបានអនុម័តនៅឡើយ។ បច្ចុប្បន្ន សេចក្តីព្រាងច្បាប់នេះ ត្រូវជាប់គាំងដោយសារហេតុផលមួយចំនួន។ ហេតុផលមួយក្នុងចំណោមនោះ ហាក់ដូចជាមកពី ការមិនឯកភាពគ្នារវាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងក្រសួងយុត្តិធម៌ អំពីតួនាទីរបស់ក្រសួងនេះ ក្នុងការគ្រប់គ្រងព្រះរាជអាជ្ញា៖ ក្រសួងស្នើថា ខ្លួនគួរតែគ្រប់គ្រងអង្គការអយ្យការ ឲ្យស្របតាមការអនុវត្តនៅប្រទេសបារាំង ចំណែកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអះអាងថា ដោយសារតែព្រះរាជអាជ្ញាជាចៅក្រម ហើយចៅក្រមមានឯករាជភាពក្រោមរដ្ឋធម្មនុញ្ញ ដូច្នេះពួកគេគួរតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឧត្តមក្រុមប្រឹក្សា។ ផលវិបាកមួយនៃការខកខានក្នុងការអនុម័តច្បាប់នេះ គឺដោយសារតែសមាជិកបីរូបរបស់ឧត្តមក្រុមប្រឹក្សា ដែលគួរតែត្រូវបានបោះឆ្នោតជ្រើសរើសដោយចៅក្រម ចេញមកពីក្នុងចំណោមសហការីរបស់ខ្លួននោះ ត្រូវបានតែងតាំងដោយក្រសួងយុត្តិធម៌ទៅវិញ តាំងពីពេលដែលឧត្តមក្រុមប្រឹក្សាត្រូវបានបង្កើតមកម្ល៉េះ។ រដ្ឋធម្មនុញ្ញចែងថា ការបោះឆ្នោតជ្រើសរើសនេះ មិនអាចធ្វើទៅបានទេ រហូតដល់ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ត្រូវបានប្រកាសឲ្យប្រើប្រាស់។

២២. វាប្រហែលជាសុច្ឆនាករណ៍នៃការប្រឈមនានារបស់កម្ពុជាដែលដប់ប្រាំពីរឆ្នាំ បន្ទាប់ពីរដ្ឋធម្ម-នុញ្ញ ត្រូវបានប្រកាសឲ្យប្រើ ច្បាប់អង្គការដែលរៀបចំប្រព័ន្ធតុលាការនេះនៅតែមិនទាន់ចូលជាធរមាន។ គួរកត់សំគាល់នៅត្រង់នេះថា ច្បាប់នេះក៏ត្រូវបានពន្យាពេលមួយផ្នែក ដោយសារតែការមិនឯកភាពគ្នាលើរបៀបក្នុងការបង្កើតតុលាការពាណិជ្ជកម្ម ឬសភាពាណិជ្ជកម្ម ដែលត្រូវបាន តម្រូវក្រោមបញ្ញត្តិនានាសំរាប់ការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោករបស់កម្ពុជា។

**គ. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**

២៣. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម(SCM) ត្រូវបានបង្កើតឡើងដោយច្បាប់ អនុលោមតាមមាត្រា ១៣២ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៤។ ព្រះមហាក្សត្រ ទ្រង់គង់ជាប្រធាននៃក្រុមប្រឹក្សានេះ ព្រមទាំងមានសមាជិកប្រាំបីរូបផ្សេងទៀត ដែលប្រាំរូបកាន់តំណែងនេះ តាមរយៈតួនាទីដែលតំរូវតាមច្បាប់ មានដូចជា៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ប្រធានតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ សមាជិកបីរូបទៀត គួរតែជាចៅក្រមចំនួនបីរូប ដែលត្រូវបានបោះឆ្នោតជ្រើសរើស ដោយអង្គចៅក្រម ពីក្នុងចំណោមសហការីរបស់ពួកគេ។

២៤. ចំណោទនានាត្រូវបានលើកឡើងទាក់ទិននឹងឯករាជភាពរបស់ឧត្តមក្រុមប្រឹក្សានេះ ដោយសារតែមានការរួមបញ្ចូលសមាជិកមកពីអង្គនីតិប្រតិបត្តិ គឺរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាសមាជិកពេញច្បាប់មួយរូប។ លើសពីនេះទៀត មាត្រា២១នៃច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចែងថា ការបោះឆ្នោតជ្រើសរើសសមាជិក មិនអាចធ្វើទៅបានទេ រហូតដល់ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ត្រូវបានប្រកាសឲ្យប្រើ។ ច្បាប់នេះ កំពុងនៅជាប់គាំងជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់រដ្ឋាភិបាល ហើយជាផលវិបាក ចាប់តាំងពីឆ្នាំ១៩៩៤មក សមាជិកទាំងបីរូបនេះ ត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

២៥. ទោះបីជាមានការយល់ឃើញថា ឧត្តមក្រុមប្រឹក្សានេះ ស្ថិតនៅក្រោមឥទ្ធិពលរបស់រដ្ឋាភិបាលក៏ដោយ ក៏នាពេលថ្មីៗនេះ ក្រុមប្រឹក្សានេះពុំឯកភាពជាមួយក្រសួងយុត្តិធម៌ លើចំណោទនៃការគ្រប់គ្រងលើអង្គការអយ្យការនោះទេ។ ក្រោមច្បាប់កម្ពុជា ព្រះរាជអាជ្ញាមានឋានៈជាចៅក្រម(ចៅក្រមឈរ) ដូច្នេះហើយ គួរតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឧត្តមក្រុមប្រឹក្សានេះ។ ក្រសួងយុត្តិធម៌ កំពុងស្វះស្វែងនាំព្រះរាជអាជ្ញា មកដាក់ក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ខ្លួន ដោយផ្អែកតាមការអនុវត្តនៅក្នុងប្រទេសមួយចំនួន ដែលប្រើប្រាស់ប្រព័ន្ធច្បាប់ស៊ីវិល។ លើសពីនេះទៀត ភាពជាប់គាំងនៃវិសោធនកម្ម ចំពោះច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ធ្វើឲ្យការរៀបចំបច្ចុប្បន្នស្ថិតនៅជានិរន្ត ដែលជាលទ្ធផល ក្រសួងយុត្តិធម៌ ដំណើរការធ្វើជាលេខាធិការដ្ឋានរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

២៦. សមាសភាពបច្ចុប្បន្នមានចៅក្រម និងព្រះរាជអាជ្ញាសកម្មដែលនាំឲ្យមានទំនាស់ផលប្រយោជន៍ជាសក្តានុពល នៅក្នុងករណីដែលចៅក្រមជាន់ខ្ពស់នានា កំពុងបំពេញមុខងារ ក្រោមការគ្រប់គ្រងរបស់សមាជិកនានានៃក្រុមប្រឹក្សានេះ។ សមាជិកនានានៃក្រុមប្រឹក្សានេះ កាន់កាប់តំណែងផ្សេងៗ ដែលមានការទទួលខុសត្រូវដ៏ធំធេងនានា ហេតុដូច្នោះហើយ ពួកគេពុំអាចនឹងផ្តោតពេលវេលា និងការយកចិត្តទុកដាក់គ្រប់គ្រាន់ ចំពោះភារកិច្ចនានាក្នុងនាមជាសមាជិកម្នាក់របស់ឧត្តមក្រុមប្រឹក្សានេះនោះទេ។ ជាផលវិបាក ឧត្តមក្រុមប្រឹក្សានេះ ជួបប្រជុំពុំបានជាទៀងទាត់នោះទេ។ ដោយឡែក នេះជាមូលហេតុមួយ ដែលអតីតលេខាធិការដ្ឋានរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវបានពិចារណាថាពុំមានលទ្ធភាពអនុវត្តការទទួលខុសត្រូវ ធ្វើអធិការកិច្ចនានារបស់ខ្លួន ហើយជាលទ្ធផល ការទទួលខុសត្រូវទាំងនេះ ត្រូវបានផ្ទេរទៅឲ្យក្រុមការងារមួយ នៅក្នុងក្រសួងយុត្តិធម៌។ ដំណោះស្រាយចំពោះបញ្ហានេះ គួរតែសមាជិកភាពរបស់ឧត្តមក្រុមប្រឹក្សានេះ ត្រូវបានកំរិតឲ្យទៅចៅក្រម ឬព្រះរាជអាជ្ញាចូលនិវត្តន៍នានា ឬសមាជិកភាពអាចទទួលបានប្រាក់បៀវត្សពេញម៉ោង សម្រាប់រយៈពេលនៃការតែងតាំង មានន័យថាចៅក្រមនានានឹងព្យួរសកម្មភាពតុលាការរបស់ខ្លួន កំឡុងពេលកាន់តំណែងនៅក្រុមប្រឹក្សានេះ។

២៧. កាលពីខែកញ្ញា ឆ្នាំ២០០៩ អនុក្រឹត្យមួយបានបង្កើត "ក្រុមជំនួយការ" ថ្មីមួយ ដើម្បីជួយដល់ក្រុមប្រឹក្សាវិន័យរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងការបំពេញការទទួលខុសត្រូវ ខាងស៊ើបអង្កេតរបស់ខ្លួន។ សមាសភាពនៃក្រុមការងារនេះ មានចៅក្រមសកម្មចំនួន១០រូប និងអនុរដ្ឋលេខាធិការមួយរូបនៃក្រសួងយុត្តិធម៌។

នេះជាការបង្កើតឧត្តមក្រុមប្រឹក្សានៅក្នុង ឧត្តមក្រុមប្រឹក្សាដែលមានភាពកំសោយដូចគ្នានៃទំនាស់ផលប្រយោជន៍ និងកង្វះពេលវេលា ដែលបានលើកបង្ហាញពីខាងលើ។ ការរួមបញ្ចូលសមាជិកនៃអង្គនីតិប្រតិបត្តិ ក៏អាចត្រូវចោទជាបញ្ហាផងដែរ។ ក្រុមការងារនេះ ត្រូវបានបង្កើតឡើង ដើម្បីបង្កើនសមត្ថភាពរបស់ឧត្តមក្រុមប្រឹក្សា ក្នុងការដោះស្រាយជាមួយនឹងការទទួលខុសត្រូវនានារបស់ខ្លួន។ ដូច្នោះហើយ ការបង្កើតរបស់វាបញ្ជាក់ថាកំណែទម្រង់របស់ឧត្តមក្រុមប្រឹក្សា ត្រូវការធានាថា ឧត្តមក្រុមប្រឹក្សានេះបង្កើនសមត្ថភាពរបស់ខ្លួន។ ប្រសិនបើ សមត្ថភាពរបស់ឧត្តមក្រុមប្រឹក្សា ត្រូវបានបង្កើននោះ ក្រុមជំនួយការនោះគួរតែត្រូវរំសាយ។

២៨. បច្ចុប្បន្ននេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពុំមានអំណាចជាក់លាក់ដើម្បី លើកស្ទួយដល់ការតែងតាំងស្ត្រីចូលក្នុងអង្គចៅក្រមនោះទេ។ សព្វថ្ងៃនេះ មានប្រមាណតែ១០ភាគរយនៃ អង្គចៅក្រមប៉ុណ្ណោះជាស្ត្រី ដែលមានចៅក្រមស្ត្រីប្រហែលជា៣៥រូប រួមបញ្ចូលទាំងព្រះរាជអាជ្ញាផងក្នុងចំណោមចៅក្រមសរុបប្រមាណជា៣៥០រូប។ មានសមាជិកជាស្ត្រីមួយរូបនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺលោកជំទាវជា លាង អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ដែលជាសមាជិកតាំងពីឆ្នាំ២០០៩មក។

២៩. កាលពីខែមករា ឆ្នាំ២០០៩ គណៈកម្មាធិការលុបបំបាត់ការរើសអើងប្រឆាំងស្ត្រីភេទ(CEDAW) បន្ទាប់ពីពិនិត្យឡើងវិញលើរបាយការណ៍របស់ប្រទេសកម្ពុជា តាមការតម្រូវក្រោមអនុសញ្ញានេះ បានផ្តល់អនុសាសន៍ នៅក្នុងការផ្តល់យោបល់ចុងក្រោយរបស់ខ្លួន(CEDAW/C/KHM/CO/3) ថា រដ្ឋាភិបាលបង្កើតនូវ "វិធានការនានា ដែលជាលទ្ធផល នឹងបង្កើនចំនួនស្ត្រីនៅក្នុងការិយាល័យតាមការជ្រើសរើស និងតែងតាំង រួមបញ្ចូលទាំងចៅក្រមផងដែរ"។ វិធានការបែបនេះ គួរតែរួមបញ្ចូលនូវវិធានការពិសេស ដើម្បីលើកស្ទួយស្ត្រី ផ្តល់ការបណ្តុះបណ្តាល និងផ្សព្វផ្សាយ ការយល់ដឹងយ៉ាងសកម្ម។ កំណែទម្រង់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគួរតែអាចផ្តល់អាណត្តិជាក់លាក់ ក្នុងការលើកស្ទួយស្ត្រី នៅក្នុងវិជ្ជាជីវៈតុលាការ ឲ្យស្របតាមអនុសាសន៍នេះ។

## ៥. បញ្ហានានានៅក្នុងនីតិវិធីគតិយុត្តិ

៣០. ថ្វីបើមានការធានារបស់រដ្ឋធម្មនុញ្ញ និងអត្ថិភាពនៃស្ថាប័នផ្សេងៗ ដើម្បីលើកស្ទួយ និងការពារឯករាជភាពរបស់ស្ថាប័ននេះក៏ដោយ ក៏អ្នករាយការណ៍ពិសេសយល់ឃើញថា អង្គចៅក្រមពុំបានធ្វើការឲ្យមានប្រសិទ្ធភាព ឯករាជ និងអនាគតិ តាមតែអាចធ្វើទៅបាននោះទេ។ ដូច្នោះហើយ លោកស្នើសុំធ្វើការលើកឡើងនូវកង្វះខាតនានានៅក្នុងនីតិវិធីតុលាការ ជាមួយនឹងជំនួយនៃករណីសិក្សាក្នុងវិស័យសិទ្ធិមនុស្សសំខាន់ៗពីរ ដែលកម្ពុជាកំពុងប្រឈមមុខនាពេលបច្ចុប្បន្នះ សិទ្ធិលំនៅដ្ឋាននិងសិទ្ធិទាក់ទងនឹងដីធ្លី និងសេរីភាពនៃការបញ្ចេញមតិ។ ឧទាហរណ៍ទាំងនេះ ឆ្លុះបញ្ចាំងពីបញ្ហាធំៗនានា ដែលកំពុងកើតឡើងនៅក្នុងប្រទេសនេះ។

## ក. សិទ្ធិលំនៅដ្ឋាន និងសិទ្ធិទាក់ទងនឹងដីធ្លី

៣១. បញ្ហានានាជុំវិញវិវាទសិទ្ធិលើដីធ្លីនានា និងបញ្ហាការបណ្ដេញចេញ បន្តនៅជាប្រធានបទក្ដៅនៅលើទំព័រសារព័ត៌មានក្នុងប្រទេសកម្ពុជានៅឡើយនាពេលបច្ចុប្បន្ននេះ។ លក្ខណៈនៃការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីរបស់រដ្ឋាភិបាលសម្រាប់គោលបំណងផ្សេងៗ បន្តនៅជាបញ្ហាដ៏ចម្បងមួយ។ ការចាប់យកដីដោយបុគ្គលមានអំណាច ហាក់ដូចជាព្រឹត្តិការណ៍ដែលកើតមានជាប្រចាំ។ ការផ្ដល់សម្បទានដីសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុននានា និងជំនួញដីធ្លី ផ្ដល់ផលវិបាកយ៉ាងធ្ងន់ធ្ងរ សម្រាប់ប្រជាជនក្រីក្រនៅតំបន់ដាច់ស្រយាលនិងទីក្រុង ក៏ដូចជាប្រជាជនជនជាតិដើមផងដែរ។[3] គិតតែក្នុងឆ្នាំ២០០៩ប៉ុណ្ណោះ យ៉ាងហោចណាស់មានការបណ្ដេញចេញចំនួន២៦ករណី ដែលបានបណ្ដាលឲ្យមានប្រជាជនប្រមាណជា២៧,០០០នាក់ ត្រូវផ្លាស់ទីលំនៅថ្មី នៅក្នុងប្រទេសកម្ពុជា។ ច្បាប់ភូមិបាលឆ្នាំ២០០១ មានចែងអំពីក្របខណ្ឌគតិយុត្តិដើម្បីដោះស្រាយបញ្ហានានានៃកម្មសិទ្ធិដីធ្លី ប៉ុន្តែមានបញ្ហាជាច្រើន ក្នុងការអនុវត្តច្បាប់នេះឲ្យបានត្រឹមត្រូវ។ ឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះហើយ ដែលដំណោះស្រាយលេខ១២/២៥ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស បានជំរុញឲ្យរដ្ឋាភិបាល បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីដោះស្រាយបញ្ហាកម្មសិទ្ធិដីធ្លីដោយសមធម៌និងឆាប់រហ័ស នៅក្នុងលក្ខណៈយុត្តិធម៌ និងបើកចំហ អនុលោមតាមច្បាប់ភូមិបាលឆ្នាំ២០០១ ដោយធ្វើការពង្រឹងការអនុវត្តច្បាប់ តាមរយៈការបង្កើតសេចក្ដីណែនាំថ្នាក់ជាតិនានាដើម្បីបំភ្លឺអំពីនីតិវិធីដែលពាក់ព័ន្ធនានា។ ច្បាប់ថ្មីស្ដីពីអស្សាមិករណ៍ បានចូលជាធរមាននៅក្នុងខែកុម្ភៈ ឆ្នាំ២០១០ ហើយសារាចររបស់រដ្ឋាភិបាល ដែលបានចេញនៅក្នុងខែធ្នូ ឆ្នាំ២០០៩ គឺជាវឌ្ឍនភាពដ៏វិជ្ជមាន នៅក្នុងទិសដៅនេះ។ ច្បាប់ស្ដីពីអស្សាមិករណ៍ ចែងអំពីកិច្ចការពារដ៏ប្រសើរមួយចំនួនសម្រាប់ម្ចាស់កម្មសិទ្ធិ។ ក្រសួងរៀបចំដែនដី បានរៀបចំដំណើរការតាក់តែងសារាចរ ដែលបើកឲ្យមានការចូលរួម ដោយអនុញ្ញាតឲ្យអង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍នានា ចូលរួមផ្ដល់គំនិតយោបល់របស់ពួកគេ។

៣២. អ្នករាយការណ៍ពិសេស មានក្ដីសោមនស្សជាមួយនឹងសំណើ ដែលធ្វើឡើងដោយប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា នៅកំឡុងពេលនៃកិច្ចប្រជុំរបស់លោកកាលពីខែមិថុនា ឆ្នាំ២០១០ ក្នុងការបង្កើតនូវក្រុមការងារក្រៅផ្លូវការចំពោះកិច្ចមួយ ដើម្បីពិនិត្យមើលលើវិវាទដីធ្លី ដែលពុំទាន់ដោះស្រាយរួច ដោយធ្វើការត្រួតពិនិត្យវិវាទទាំងនោះ ហើយស្នើជាអនុសាសន៍នានា ដើម្បីស្វែងរកដំណោះស្រាយនៅក្នុងលក្ខណៈគតិយុត្តិ និងយុត្តិធម៌មួយ។ សមាសភាពរបស់ក្រុមការងារនេះ មានតំណាងម្នាក់មកពីការិយាល័យរបស់លោក (គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា) តំណាងម្នាក់ មកពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា(OHCHR-Cambodia) និងតំណាងមួយចំនួនទៀត មកពីអង្គការសង្គមស៊ីវិល ដែល

[3] នៅខែឧសភា ឆ្នាំ២០១០ យោងតាមព័ត៌មានសាធារណៈរបស់ក្រសួងកសិកម្ម សម្បទានដីសេដ្ឋកិច្ចត្រូវបានផ្ដល់ឲ្យក្រុមហ៊ុនចំនួន៨៥ ដែលគ្របដណ្ដប់ផ្ទៃដីសរុបទំហំ៩៥៦,៦៩០ហិតា។ តាមការវាយតំលៃរបស់អង្គការសង្គមស៊ីវិល ផ្ទៃដីមានទំហំធំជាងនេះ។ សូមចូលទៅhttp://www.elc.maff.gov.kh/index.html

ធ្វើការលើបញ្ហាដីធ្លី។ ដោយយល់ឃើញអំពីអសមត្ថភាពនៃស្ថាប័នដែលមានស្រាប់នានា ក្នុងការដោះស្រាយវិវាទមួយចំនួន រួមផ្សំនឹងកង្វះនៃសំណាងសម្រាប់បុគ្គលនានា អ្នករាយការណ៍ពីសេស បានស្វាគមន៍សំណើនោះថាប្រកបដោយភាពស្ថាបនា ដោយថ្លែងថា យន្តការក្រៅផ្លូវការថ្មីនេះ ពុំជំនួសឲ្យ ឬបន្ថយអានុភាពរបស់យន្តការនានាដែលមានស្រាប់ ដូចជាគណៈកម្មការសុរិយោដី តុលាការ ឬអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីនោះទេ។ អ្នករាយការណ៍ពិសេស លើកទឹកចិត្តឲ្យមានកិច្ចពិភាក្សានានាដែលប្រកបដោយសហប្រតិបត្តិការ ក្នុងចំណោមអ្នកពាក់ព័ន្ធនានា អំពីតួនាទីសមស្រប ដែលយន្តការបែបនេះ អាចធ្វើទៅបាន ក្នុងការរួមចំណែកស្វែងរកដំណោះស្រាយសម្រាប់ទំនាស់ដីធ្លីពិបាកៗ ឬករណីបណ្តេញចេញនានា។ កម្មវត្ថុរបស់ក្រុមការងារនេះគួរតែជាកិច្ចសន្ទនាបែបស្ថាបនា ដោយតម្លាភាព រវាងរដ្ឋាភិបាល OHCHR-Cambodia និងសង្គមស៊ីវិល (រួមទាំងសម្លេងរបស់សហគមន៍នានា) ដើម្បីធ្វើឲ្យកិច្ចការនេះ ក្លាយជាការកិច្ចខិតខំប្រឹងប្រែងដ៏មានសារៈប្រយោជន៍។ អ្នករាយការណ៍ពិសេស សង្ឃឹមថា ក្រុមការងារមួយ អាចត្រូវបានបង្កើតឡើងក្នុងពេលអនាគតដ៏ឆាប់ៗនេះ។

## ខ. សេរីភាពនៃការបញ្ចេញមតិ

៣៣. សេរីភាពនៃការបញ្ចេញមតិ គឺជាសរសៃឈាមនៃលទ្ធិប្រជាធិបតេយ្យ ប៉ុន្តែវាបន្តនៅជាកង្វល់ដ៏ចម្បងមួយនៅក្នុងប្រទេសកម្ពុជា។ ហាក់ដូចជាពុំមានការបកស្រាយសមស្រប ចំពោះបទបរិហាកេរ្តិ៍នៃបទប្បញ្ញត្តិព្រហ្មទណ្ឌសម័យអន្តរកាល(UNTAC)ឡើយ ដែលជួយធ្វើឲ្យមានសមាមាត្ររវាងកិច្ចការពារកិត្តិយសឯកជន និងការផ្តល់ព័ត៌មានជាសាធារណៈដែលពាក់ព័ន្ធនឹងបញ្ហានានានៃផលប្រយោជន៍សាធារណៈ។ ច្បាប់ទាក់ទិននឹងបទបរិហាកេរ្តិ៍និងបទផ្សាយព័ត៌មានមិនពិត ត្រូវបានប្រើប្រាស់យ៉ាងសំរិតសំរាំងបំផុត និងក្នុងលក្ខណៈលំអៀងប្រឆាំងនឹងអ្នកសារព័ត៌មាន សកម្មជនសិទ្ធិមនុស្ស និងអ្នកដឹកនាំក្នុងជួរនយោបាយនានា។ ចំណែកតុលាការហាក់ដូចជាពុំបកស្រាយច្បាប់ និងការកំរិតលើសេរីភាពនៃការបញ្ចេញមតិ ឲ្យស្របតាមច្បាប់ជាតិនោះទេ និងមិនអនុលោមតាមបទដ្ឋានអន្តរជាតិ។ អភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្របីរូប មានលោកសម រង្ស៊ី លោកស្រីមូ សុខហួ និងលោកហូ វ៉ាន់ ដែលសុទ្ធតែមកពីគណៈបក្សប្រឆាំង ត្រូវបានដក នៅក្នុងឆ្នាំ២០០៩ ដើម្បីបើកផ្លូវសម្រាប់ឲ្យមានការធ្វើបណ្តឹងអាជ្ញាពីបទបរិហាកេរ្តិ៍ និង/ឬបទផ្សាយព័ត៌មានមិនពិត ប្រឆាំងនឹងពួកគេ។

៣៤. នៅក្នុងបណ្តឹងទាំងនោះ ពុំមានតំណាងរាស្ត្រជាប់ចោទណាម្នាក់ ត្រូវបានផ្តល់ឱកាសឲ្យដាក់រឿងក្តីរបស់ពួកគេ ចូលទៅរដ្ឋសភា ឬធ្វើការបដិសេធតបទៅនឹងបណ្តឹងទាំងនោះឡើយ។ ការអនុវត្តបែបនេះប្រឆាំងនឹងគោលការណ៍មូលដ្ឋាននៃយុត្តិធម៌ ដែលតំរូវថា គ្រប់ជនដែលត្រូវបានចោទប្រកាន់ពីអំពើល្មើស ឬពីការប្រព្រឹត្តបទល្មើស ត្រូវតែទទួលបាននូវឱកាសក្នុងការបង្ហាញនូវរឿងក្តីរបស់ខ្លួន មុនពេលបណ្តឹង ត្រូវបានចាត់ការប្រឆាំងនឹងពួកគេ។ ទោះជាដូច្នោះក្តី តុលាការពុំអើពើនឹងបញ្ហាបែបនោះឡើយ នៅពេលដែលសម្រេចផ្តន្ទា

ទោសពួកគេពីបទបរិហាកេរ្តិ៍។ ដូចគ្នាផងដែរ ការចោទប្រកាន់ និងដាក់ពន្ធនាគារអ្នកសារព័ត៌មាន ដូចជាលោក ហង្ស ចក្រា (និពន្ធនាយកនៃសារព័ត៌មានប្រឆាំង *ខ្មែរម្ចាស់ស្រុក*) និងអ្នកសារព័ត៌មានម្នាក់ផ្សេងទៀត (លោក រស់ សុឃិត) ពុំគួរកើតឡើងនៅក្នុងប្រទេសដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យជាធម្មតានោះទេ ដោយសារតែសកម្មភាពរបស់ពួកគេពុំបានបំពានលើច្បាប់ និងសណ្តាប់ធ្នាប់សាធារណៈឬក៏ដាក់ការគំរាមកំហែងដល់សន្តិសុខជាតិរបស់ប្រទេសកម្ពុជានោះឡើយ។

៣៥. ករណីរបស់លោកហង្ស ចក្រា ជាទឡ្ហីករណ៍ពិសេសមួយដែលឆ្លុះបញ្ចាំងអំពីការអនុវត្តនៃវិស័យតុលាការនៅក្នុងប្រទេសកម្ពុជា។ កាលពីខែឧសភា ឆ្នាំ២០០៩ លោកបានប្រឈមនឹងបណ្តឹងបទបរិហាកេរ្តិ៍ដែលប្តឹងដោយមេធាវីតំណាងឲ្យលោកសុខ អាន (ឧបនាយករដ្ឋមន្រ្តី និងរដ្ឋមន្រ្តីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្រ្តី) បន្ទាប់ពីកាសែតរបស់លោកចុះផ្សាយនូវអត្ថបទមួយ កាលពីថ្ងៃទី៥-៧ ខែមេសា ឆ្នាំ២០០៩ ក្រោមចំណងជើងថា "ហ៊ុន សែន បង្រ្កាបមន្រ្តីអាក្រក់ និងពុករលួយដែលធ្វើការនៅជុំវិញសុខ អាន"។ អត្ថបទនោះបានថ្លែងថា លោកសុខ អាន ពុំទទួលបានការទុកចិត្តពីលោកនាយករដ្ឋមន្រ្តីដូចពីអតីតកាលឡើយ។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ លោកបានចុះផ្សាយអត្ថបទមួយទៀត ក្រោមចំណងជើងថា "មន្រ្តីស្មោះត្រង់នឹងសុខ អាន ប្រឈមនឹងការដកដំណែង"។ អត្ថបទទាំងពីរនេះ ត្រូវបានប្រើប្រាស់ដោយតុលាការរាជធានីភ្នំពេញ និងដោយសាលាឧទ្ធរណ៍ ជាភស្តុតាង ក្នុងការស្វែងរកពិរុទ្ធភាពរបស់គាត់ពីបទផ្សាយព័ត៌មានមិនពិត និងផ្តន្ទាទោសឲ្យជាប់ពន្ធនាគារមួយឆ្នាំ ទោះបីជាអត្ថបទរបស់គាត់ពុំបានដាក់ការគំរាមកំហែងដល់ច្បាប់ សណ្តាប់ធ្នាក់សាធារណៈ ឬសន្តិ-សុខជាតិរបស់ប្រទេសក៏ដោយ។

៣៦. អ្វីដែលគួរឲ្យចាប់អារម្មណ៍ផងដែរនោះគឺថា នៅកំឡុងពេលចាត់ការសំណុំរឿងនេះ តុលាការទាំងពីរថ្នាក់ ពុំបានយកច្បាប់សារព័ត៌មានមកអនុវត្តន៍នោះទេ ដែលតាមច្បាប់នោះ ត្រូវតម្រូវឲ្យភាគីរងការប៉ះពាល់ពីការចុះផ្សាយនោះ ស្វះស្វែងឲ្យលោកហង្ស ចក្រា ដកចេញនូវអត្ថបទនោះ ឬមានសិទ្ធិដើម្បីឆ្លើយតបទៅនឹងអត្ថបទនោះ។ ភ្លាមៗ បន្ទាប់ពីត្រូវបានផ្តន្ទាទោសដោយតុលាការរាជធានីភ្នំពេញ លោកហង្ស ចក្រា ត្រូវបានឃាត់ខ្លួននៅខេត្តបាត់ដំបង រួចបញ្ជូនទៅមណ្ឌលកែប្រែទី១(ម១)។ លោកបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនោះ ប៉ុន្តែសាលាឧទ្ធរណ៍ សម្រេចរក្សាសាលក្រមរបស់សាលាដំបូងនោះ។ លោកហង្ស ចក្រា ពុំបានប្តឹងសាទុក្ខសាលដីការបស់សាលាឧទ្ធរណ៍ ទៅតុលាការកំពូលនោះទេ ដោយលោកជឿថា វាជាការឥតប្រយោជន៍។ នៅកំឡុងបេសកកម្មរបស់លោក នៅក្នុងខែមករា ឆ្នាំ២០១០ អ្នករាយការណ៍ពិសេស បានចុះសួរសុខទុក្ខលោកហង្ស ចក្រានៅក្នុងពន្ធនាគារ។ ក្រោយមកទៀត លោកត្រូវបានព្រះរាជទានទោសដោយព្រះមហាក្សត្រ នៅក្នុងខែមេសា ឆ្នាំ២០១០ និងត្រូវបានដោះលែង។

៣៧. សាលក្រមរបស់តុលាការទាំងពីរ ផ្តោតសំខាន់ទៅលើចេតនាអសុទ្ធចិត្ត នៃការសរសេរអត្ថបទនោះ ព្រមទាំងព័ត៌មាននោះជារឿងមិនពិត។ តុលាការ ពុំបានទាញហេតុផលផ្លូវច្បាប់ អំពីមូលហេតុ ឬតាមរបៀបណា ដែលអត្ថបទរបស់លោកហង្ស ចក្រា អាចនឹងប៉ះពាល់ដល់សន្តិសុខសាធារណៈ ដែលជាធាតុផ្សំដ៏សំខាន់នៃបទផ្សាយព័ត៌មានមិនពិត ក្រោមមាត្រា៦២ នៃបទប្បញ្ញត្តិព្រហ្មទណ្ឌសម័យអន្តរកាល(UNTAC)។ វាគួរឲ្យចាប់អារម្មណ៍ខ្លាំងណាស់ ដែលព្រះរាជអាជ្ញាពុំបានស៊ើបអង្កេតករណីនោះទេ ប៉ុន្តែបានបញ្ជូនសំណុំរឿងនោះដោយផ្ទាល់ទៅចៅក្រមជំនុំជម្រះតែម្តង។ ចៅក្រមស៊ើបសួរ ក៏ពុំបានចូលរួមក្នុងការស៊ើបសួរលើរឿងក្តីនេះផងដែរ។ អត្ថបទទាំងនោះ ត្រូវបានចុះផ្សាយនៅក្នុងខែមេសា និងឧសភា ឆ្នាំ២០០៩ ហើយលោកហង្ស ចក្រា ត្រូវបានផ្តន្ទាទោស នៅក្នុងខែមិថុនា ដែលជាការផ្តន្ទាទោសមួយដ៏ឆាប់រហ័សបំផុត ទោះជាតាមបទដ្ឋានណាក៏ដោយ។ ការនេះ ធ្វើឲ្យគេមានការសង្ស័យថា តុលាការមានចេតនាផ្តន្ទា និងដាក់ទោសលោកហង្ស ចក្រា។

៣៨. សវនាការមានភាពឆាប់រហ័សខ្លាំងពេក ដែលធ្វើឲ្យមេធាវីរបស់លោកហង្ស ចក្រា ពុំមានពេលវេលា ក្នុងការរៀបចំការពាររឿងក្តីនោះ។ លោកបានសុំឲ្យចៅក្រមលើកសវនាការទៅពេលក្រោយ ប៉ុន្តែសំណើនោះត្រូវបានបដិសេធ។ ទាំងលោកហង្ស ចក្រា និងមេធាវីរបស់លោក សុទ្ធតែពុំមានឱកាសដាក់សេចក្តីទាញហេតុផល ទៅក្នុងភស្តុតាងដោះបន្ទុក។ សវនាការមានរយៈពេលប្រហែលជាមួយម៉ោង ហើយលោកហង្ស ចក្រា ត្រូវបានសម្រេចថាមានពិរុទ្ធភាពដោយកំបាំងមុខ។ បន្ទាប់ពីត្រូវបានឃាត់ខ្លួន មេធាវីរបស់លោក ក៏បានប្តឹងឧទ្ធរណ៍។ មេធាវីការពារ បានធ្វើសេចក្តីទាញហេតុផលយ៉ាងរឹងមាំថា នេះពុំមែនជាបទព្រហ្មទណ្ឌនោះទេ ប៉ុន្តែជាបញ្ហារដ្ឋប្បវេណីសុទ្ធសាធ ដោយសារតែអត្ថបទរបស់លោកហង្ស ចក្រា ពុំបង្កឲ្យមានភាពរំជើបរំជួលដល់សាធារណៈ ឬក៏ដាក់ការគំរាមកំហែងដល់សន្តិសុខជាតិនោះទេ ប៉ុន្តែគណៈវិនិច្ឆ័យរបស់សាលាឧទ្ធរណ៍ ពុំអនុញ្ញាតឲ្យគាត់ ដាក់បញ្ចូលសេចក្តីទាញហេតុផលរបស់គាត់ឡើយ។ អង្គចៅក្រមផ្តោតការយកចិត្តទុកដាក់របស់ពួកគេ ទៅលើតែធ្វើឲ្យលោកហង្ស ចក្រា សារភាពចំពោះបទចោទប្រកាន់នោះ ជាជាងចូលទៅស្វែងរកអង្គហេតុនៃរឿងក្តីនោះ។

៣៩. អ្នករាយការណ៍ពិសេសដឹងថា មានការរីកចំរើនជាវិជ្ជមានមួយចំនួន នៅក្នុងរឿងក្តីកន្លងមកទាក់ទិននឹងការបកស្រាយនៃច្បាប់ស្តីពីបទផ្សាយព័ត៌មានមិនពិត។ ឧទាហរណ៍បែបនេះមួយ គឺសាលក្រមរបស់តុលាការខេត្តតាកែវ ដែលបានសម្រេចឲ្យអ្នកការពារសិទ្ធិមនុស្សពីររូប (លោកជាប ឈីវ និងលោកខឹម សារុន) អ្នកសារព័ត៌មានអាស៊ីសេរីម្នាក់(លោកសុខ សេរី) និងតំណាងសហគមន៍ចាមពីររូប(លោកនី សាន និងសែបសឹន) រួចខ្លួនពីបទផ្សាយព័ត៌មានមិនពិត។ បទចោទប្រកាន់នោះ ត្រូវបានប្តឹងប្រឆាំងនឹងបុគ្គលទាំងប្រាំរូប បន្ទាប់ពីការសម្ភាសន៍នៅវិទ្យុអាស៊ីសេរី កាលពីខែធ្នូ ឆ្នាំ២០០៨ ដែលនៅកំឡុងនៃបទសម្ភាសន៍នោះ ពួកគេបានចោទអំពីអំពើពុករលួយ ដែលបានប្រព្រឹត្តដោយមន្ត្រីមូលដ្ឋានក្នុងភូមិកំពង់ទួល ខេត្តតាកែវ។ ពួកគេត្រូវបានចោទប្រកាន់នៅក្នុងខែតុលា ឆ្នាំ២០០៩ ជាអាទិ៍ ពីបទផ្សាយព័ត៌មានមិនពិតក្រោមបទប្បញ្ញត្តិនៃច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល(UNTAC)។ បទល្មើសនេះ ទាមទារនូវធាតុផ្សំនៃចេតនាទុច្ចរិត និងភស្តុតាង ដែលបញ្ជាក់ថា ព័ត៌មានដែល

បានផ្សព្វផ្សាយទៅនោះ នឹង "ប៉ះពាល់ ឬដែលទំនងនឹងប៉ះពាល់ដល់សន្តិសុខសាធារណៈ"។ ក្នុងការសម្រេចចិត្តទំលាក់ការចោទប្រកាន់ពីបទផ្សាយព័ត៌មានមិនពិត តុលាការខេត្តតាកែវបានថ្លែងយ៉ាងជាក់លាក់ថា ពុំមានចេតនាទុច្ចរិតគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទ។ នេះគឺជាការរីកចំរើនដ៏គួរឲ្យស្វាគមន៍ ហើយអ្នករាយការណ៍ពិសេសសង្ឃឹមថា តុលាការផ្សេងៗទៀត នឹងយកគំរូតាមការសម្រេចនេះ ចំពោះករណីបទបរិហាកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិតនាពេលអនាគត ដោយស្វែងរកឲ្យឃើញនូវអង្គហេតុរបស់រឿងក្តី និងផ្តល់នូវការទាញហេតុផលគតិយុត្តិសម្រាប់សាលក្រមរបស់ពួកគេ។ ទោះជាដូច្នោះក្តី អ្នករាយការណ៍ពិសេសក៏សង្ឃឹមផងដែរថា បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាចំពោះរឿងក្តីនេះ នឹងពុំនាំឲ្យមានការបដិសេធសាលក្រមនេះ នោះទេ។

## ៦. ការប្រឈមចម្បងៗសម្រាប់វិស័យតុលាការ

៤០. នៅក្នុងប្រទេសប្រកាន់យកលទ្ធិប្រជាធិបតេយ្យ តុលាការគួរតែមានលទ្ធភាពធ្វើឲ្យយុត្តិធម៌ មានឧត្តមានុភាពទៅលើនយោបាយផ្តាច់ការ។ ជាបឋម វាគឺជាភារកិច្ចរបស់អង្គចៅក្រម ក្នុងការការពារឯករាជភាព និងបូរណភាពរបស់ខ្លួន ប្រឆាំងនឹងការជ្រៀតជ្រែកខាងនយោបាយ និងហិរញ្ញវត្ថុ ពីខាងក្រៅ។ តុលាការមានកាតព្វកិច្ចស្វែងរកយុត្តិធម៌ស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់ ដែលជាផ្នែកមួយនៃនិយាម និងបទដ្ឋានយុត្តិធម៌ ភាពត្រឹមត្រូវ និងនីតិវិធីត្រឹមត្រូវដែលត្រូវបានទទួលជាសកល ប៉ុន្តែតុលាការខ្វះនូវរចនាសម្ព័ន្ធរូបវន្ត និងគតិយុត្តិដែលចាំបាច់ដើម្បីផ្តល់លទ្ធភាពឲ្យស្ថាប័ននេះ អាចធ្វើការងាររបស់ខ្លួន ក្នុងនាមជាអង្គតុលាការឯករាជមួយ។ តាមការទទួលស្គាល់របស់រដ្ឋាភិបាលផ្ទាល់ខ្លួន "វិស័យតុលាការ ពុំទាន់ទទួលបានការទុកចិត្តទាំងស្រុង ពីសាធារណៈនៅឡើយ ។"[4] តាមរយៈការពង្រឹងឯករាជភាពរបស់ប្រព័ន្ធតុលាការ និងបង្ហាញពីការប្តេជ្ញាចិត្តរបស់ស្ថាប័ននេះ ក្នុងការប្រកាន់យកនីតិរដ្ឋដ៏ពិតប្រាកដ និងពង្រឹងលទ្ធិប្រជាធិបតេយ្យឲ្យរឹងមាំឡើងនោះ ថ្នាក់ដឹកនាំនយោបាយ នឹងបញ្ជូនសារដ៏វិជ្ជមានមួយទៅដល់ប្រជាពលរដ្ឋរបស់ខ្លួន រដ្ឋាភិបាល និងតុលាការខ្លួនឯងផ្ទាល់ ព្រមទាំងសហគមន៍អន្តជាតិ។ អ្នករាយការណ៍ពិសេសយល់ឃើញថា ប្រព័ន្ធតុលាការដ៏មានឯករាជ្យភាព មិនគ្រាន់តែដើរតួសំខាន់ក្នុងការកសាងសង្គមមួយ ដែលកាន់តែមានយុត្តិធម៌ និងលទ្ធិប្រជាធិបតេយ្យប៉ុណ្ណោះទេ ប៉ុន្តែក៏នឹងលើកស្ទួយដល់មុខមាត់ប្រទេសជាតិនៅលើឆាកអន្តរជាតិផងដែរ។ ឧទាហរណ៍ ដើម្បីរក្សាបាននូវសន្ទុះ និងពន្លឿននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចនោះ ប្រទេសកម្ពុជា នឹងត្រូវការទាក់ទាញនូវវិនិយោគទុនបរទេសឲ្យកាន់តែច្រើនឡើង នៅក្នុងវិស័យសេដ្ឋកិច្ចសមរម្យនានា។ កត្តាសំខាន់បំផុតមួយចំនួន ដែលភាគច្រើននៃអ្នកវិនិយោគបរទេសនានាយកទៅពិចារណា មុនពេលសម្រេចចិត្ត ដើម្បីវិនិយោគនូវចំនួនសាច់ប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ ទៅក្នុងប្រទេសណាមួយនោះ គឺតុលាការដ៏មានឯករាជភាព និងប្រព័ន្ធយុត្តិធម៌ដ៏រឹងមាំ។

[4] របាយការណ៍ថ្នាក់ជាតិដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សដោយប្រទេសកម្ពុជា៖ (A/HRC/WG.6/6KHM/1, para 101)

៤១. ទោះបីជារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងអំពីការបែងចែកអំណាចរវាង អង្គការធំទាំងបីរបស់រដ្ឋក៏ដោយ ក៏នៅក្នុងការអនុវត្តជាក់ស្តែង គេពិបាកនឹងញែកឯករាជភាពនៃអង្គការទាំងបី ឲ្យដាច់ស្រឡះពីគ្នាណាស់ ហើយអង្គនីតិប្រតិបត្តិ តែងមានឧត្តមានុភាពលើអង្គតុលាការ ទាំងតាមរូបភាពនៃការផ្តល់ធនធាននានាដល់តុលាការ ឬក្នុងការតែងតាំងតំណែងផ្សេងៗ នៃវិស័យតុលាការ។ ការលំបាក នៅតែជាការប្រឈមសម្រាប់ប្រទេសនេះ ក្នុងការអនុវត្តនីតិរដ្ឋ លើកស្ទួយ និងការពារសិទ្ធិរបស់ប្រជាពលរដ្ឋ។ អ្នករាយការណ៍ពិសេស មានការយល់ដឹងអំពីផលប៉ះពាល់ នៃអតីតកាលដ៏ខ្លោចផ្សា លើប្រព័ន្ធតុលាការ ហើយសម្តែងនូវការកោតសរសើរចំពោះកិច្ចខិតខំក្នុងការកសាងវិស័យនេះឡើងវិញ។ ទោះជាដូច្នោះក៏ដោយ ប្រព័ន្ធតុលាការនៅត្រូវការពេលវេលាយូរទៀត ដើម្បីបញ្ចូល និងស្ថាបនានូវឯករាជភាពរបស់ខ្លួន ចំណែកឯអង្គនីតិប្បញ្ញត្តិ និងអង្គនីតិប្រតិបត្តិ ត្រូវតែអនុម័តនូវវិធានការមួយចំនួនដើម្បីផ្តល់លទ្ធភាពឲ្យអំណាចតុលាការអាចសម្រេចបាននូវកិច្ចការនេះ។ ជារឿយៗ និងជាពិសេស នៅក្នុងរឿងក្តីនយោបាយធំៗ ប្រព័ន្ធតុលាការ ហាក់ដូចជាបានអនុញ្ញាតឲ្យខ្លួន ត្រូវបានប្រើប្រាស់ ឬយកធ្វើជាឧបករណ៍សម្រាប់គោលបំណងនយោបាយ ឬឯកជនសុទ្ធសាធ។

៤២. ប្រជាពលរដ្ឋពុំមានទំនុកចិត្តថា តុលាការនឹងផ្តល់យុត្តិធម៌ដោយឥតលំអៀងនោះទេ។ ជាផលវិបាក ប្រជាពលរដ្ឋស្វះស្វែងរកវិធីសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនានា ដែលនាំឲ្យកាន់តែរង្គោះរង្គើដល់នីតិរដ្ឋថែមទៀត។ នៅក្នុងវិវាទដីធ្លី សហគមន៍នានាមានទំនោរចង់តែគេចពីប្រព័ន្ធតុលាការ ដោយធ្វើញត្តិទៅកាន់អ្នកដឹកនាំកំពូលៗ ឲ្យជួយធ្វើអន្តរាគមន៍ដល់ពួកគេ ដែលការនេះ កាន់តែពង្រឹងដល់អំណាចនីតិប្រតិបត្តិដែលរឹងមាំរួចស្រេចហើយនោះ ឲ្យកាន់តែរឹងមាំថែមទៀត។ មុនពេលសង្គ្រាមស៊ីវិល ព្រះបាទនរោត្តម សីហនុ ជាតួអង្គចម្បងដែលទទួលញត្តិទាំងនេះ។ បច្ចុប្បន្ន ប្រជាពលរដ្ឋជាច្រើនក្រុម បន្តបន្ទាប់គ្នាសឹងតែយកស្ទួនច្បារទល់មុខលំនៅដ្ឋានរបស់លោកនាយករដ្ឋមន្ត្រីទាំងនៅខេត្តកណ្តាល និងភ្នំពេញ ធ្វើជាទីតាំងបោះជំរុំជាអចិន្ត្រៃយ៍ ទៅហើយ។ លោកនាយករដ្ឋមន្ត្រី ធ្វើអន្តរាគមន៍ជាញឹកញាប់ដើម្បីឆ្លើយតបទៅនឹងការធ្វើញត្តិដោយផ្ទាល់របស់ប្រជាពលរដ្ឋឯកជននានា។

៤៣. គុណភាពនៃនីតិវិធីទាញហេតុផលគតិយុត្តិ នៅក្នុងពេលសវនាការ មានកំរិតទាប គួរឲ្យអស់សង្ឃឹម ហើយជាញឹកញាប់សឹងតែគ្មានផង។ ទោះជានៅក្នុងកំណែទម្រង់ថ្មីៗនេះ បានដាក់ជាលក្ខខណ្ឌតម្រូវ ឲ្យតុលាការបញ្ចូលការទាញហេតុផលសំអាងហេតុទៅក្នុងសាលក្រមរបស់ខ្លួនក្តី ក៏ចៅក្រមនានាកម្រនឹងបញ្ចូលការទាញហេតុផលបែបនោះ ដើម្បីគាំទ្រសាលក្រមរបស់ខ្លួនណាស់។ ទំនាក់ទំនងហេតុផលនៃការទាញហេតុផលគតិយុត្តិមួយចំនួន ជាទូទៅមានលក្ខណៈពិបាកយល់។ ទោះបីជានៅក្នុងរឿងក្តីកំរិតខ្ពស់នានា ដូចជាទាក់ទិននឹងសមាជិកសភាលោកស្រីមូ សុខហួរ និងសមាជិកថ្នាក់ដឹកនាំគណៈប្រឆាំង ក៏តុលាការនៅគ្រប់ជាន់ថ្នាក់ ពុំបានផ្តល់ការទាញហេតុផលគតិយុត្តិ ដែលគួរឲ្យជឿជាក់បាន ដើម្បីគាំទ្រសាលក្រមរបស់ពួកគេនោះទេ។ ជាជាងស្វែងរកអង្គសេចក្តីនៃរឿងក្តី អង្គតុលាការមានទំនោរចេញសាលក្រម ផ្អែកទៅលើតែមូលដ្ឋានបច្ចេកទេសសុទ្ធ

សាធ។ ក្នុងឧទាហរណ៍មួយទៀត វិវាទដីធ្លីនៅកោះពេជ្រ(កោះមួយក្នុងទន្លេបាសាក់) សាលារាជធានីភ្នំពេញ បានដាក់បណ្តឹងទៅតុលាការរាជធានីភ្នំពេញប្រឆាំងនឹងគ្រួសារប្រជាពលរដ្ឋមួយចំនួនដែលតាំងទីលំនៅលើកោះនោះ។ បណ្តឹងនេះផ្ទុយនឹងច្បាប់ ដោយសារតែដីនោះពុំមានចុះបញ្ជី ដូច្នោះហើយ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មាធិការសុរិយោដី ដូចមានចែងក្រោមមាត្រា៤៧ នៃច្បាប់ភូមិបាល ឆ្នាំ២០០១។ មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ (CLEC ដែលជាអង្គការជំនួយផ្នែកច្បាប់មួយនៅកម្ពុជា) មេធាវីនានាដែលតំណាងឲ្យគ្រួសារទាំងនោះ បានស្នើសុំផ្ទេររឿងក្តីនេះទៅឲ្យគណៈកម្មាធិការសុរិយោដីវិញ ប៉ុន្តែតុលាការនៅតែបន្តនីតិវិធីលើរឿងក្តីនោះ ហើយបានសម្រេចឲ្យគ្រួសារទាំងនោះចាកចេញ និងឲ្យទទួលយកសំណងក្នុងអត្រាទាបជាងអត្រាទីផ្សារ។ មេធាវីទាំងនោះ បានស្នើសុំឲ្យចាត់របៀប រហូតទាល់តែរឿងក្តីចំបង (ផ្ទេររឿងទៅគណៈកម្មាធិការសុរិយោដី) ត្រូវបានសម្រេច។ សាលារាជធានីធ្វើសំណើតប ហើយតុលាការរាជធានីក៏បានសម្រេចឲ្យសាលារាជធានីឈ្នះ។ មានការអះអាងមកថា ចៅក្រមបាននិយាយថាលោកពុំចង់ស្តាប់ភស្តុតាងដែលមេធាវីលោកបង្ហាញអំពីសិទ្ធិភោគៈនោះទេ ដោយថ្លែងថា "សាលារាជធានីឲ្យរឿងក្តីមកខ្ញុំកាន់" ហើយ។ ពុំមានការវិភាគគតិយុត្តិទៅលើអង្គហេតុនៃរឿងក្តីនោះទេ។ គ្រួសារពីរបានសម្រេចប្តឹងឧទ្ធរណ៍។ សាលាឧទ្ធរណ៍សម្រេចតំកល់សាលក្រមរបស់សាលាដំបូងទុកជាបានការ។ មានរឿងក្តីស្រដៀងគ្នានេះជាច្រើនទៀត។

៤៤. ដោយសារតែអវត្តមាននៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ក្នុងការធានាដល់មុខតំណែងនិងឯករាជភាពរបស់ពួកគេ អង្គចៅក្រមហាក់ដូចជាកំពុងបំពេញមុខងាររបស់ខ្លួននៅក្នុងបរិយាកាសខ្លាចរអា ទោះតិច ឬច្រើន ដោយពួកគេត្រូវប្រុងប្រយ័ត្ន ចៀសវាងបោះជំហានណាមួយ ដែលអាចទទួលរងការរិះគន់ពីសំណាក់មន្ត្រីមានអំណាច និងមានតំណែងធំៗ។ របៀបដែលពួកគេឆ្លើយតបទៅនឹងបរិយាកាសបែបនេះ ស្តែងបង្ហាញយ៉ាងច្បាស់ពីឥរិយាបទរបស់ពួកគេ នៅក្នុងរឿងក្តីដែលពាក់ព័ន្ធនឹងនយោបាយ។ បច្ចុប្បន្ន អង្គចៅក្រមស្ថិតក្រោមការគ្រប់គ្រងនៃច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ហើយអ្នកដែលមានអាយុច្រើនជាង៦០ឆ្នាំ អាចដាក់បង្ខំឲ្យចូលនិវត្តន៍តាមឆន្ទានុសិទ្ធិរបស់អំណាចនីតិប្រតិបត្តិ ឬរក្សាតំណែងរហូតដល់អាយុ៦៥ឆ្នាំ សម្រាប់ភក្តីភាពខាងនយោបាយ។ ព្រះរាជអាជ្ញានានា មានទំនោរទទួលកាន់បណ្តឹងព្រហ្មទណ្ឌ ពីមន្ត្រីនយោបាយជាន់ខ្ពស់នានា ដោយមិនស្ទាក់ស្ទើរ -- ជាពិសេសករណីបណ្តឹងបទបរិហាកេរ្តិ៍ និងផ្សាយព័ត៌មានមិនពិត ហើយសម្រាប់រឿងក្តីបែបនេះ តែងតែបញ្ចប់ដោយការផ្តន្ទាទោស ទោះបីជាខ្វះភស្តុតាងដាក់បន្ទុក ហើយភស្តុតាងដោះបន្ទុកមានបរិបូរណ៍ក៏ដោយ។ អង្គចៅក្រមនៅសាលាដំបូង ហាក់ដូចជាមានការខ្លាចរអា ក្នុងការចាត់វិធានការ ដោយឯករាជ្យ ជាងអង្គចៅក្រមនៅតុលាការជាន់ខ្ពស់។ ជាលទ្ធផល អត្រានៃបណ្តឹងឧទ្ធរណ៍ ឡើងទៅដល់តុលាការកំពូលមានកំរិតខ្ពស់។

៤៥. ជាទឡ្ហីករណ៍ កាលពីថ្មីៗនេះ តុលាការកំពូលបានចេញសាលដីកាក្នុងខែធ្នូ ឆ្នាំ២០០៨ សម្រេចដោះលែងបុរសពីររូប ដែលត្រូវបានផ្តន្ទាទោសពីបទឃាតកម្មលើប្រធានសហព័ន្ធសហជីព លោកជា វិជ្ជា ហើយ

បានស្នើឲ្យសាលាឧទ្ធរណ៍ធ្វើការត្រួតពិនិត្យលើសំណុំរឿងនោះឡើងវិញ។ រឿងក្តីរបស់បុរសទាំងពីររូប បានក្លាយទៅជាបញ្ហាដែលទទួលបានការចាប់អារម្មណ៍បំផុត ដោយសារ ស្ទើតែគ្មានភស្តុតាងដាក់បន្ទុកប្រឆាំងនឹងពួកគេទាល់តែសោះ រីឯភស្តុតាងដោះបន្ទុកមានច្រើនលើសលុប។ សវនាការនៅដំណាក់កាលសាលាដំបូងពុំអនុលោមតាមបទដ្ឋាននីតិវិធីជាមូលដ្ឋាននោះទេ ហើយតុលាការឧទ្ធរណ៍ទទួលរងនូវការរិះគន់យ៉ាងធ្ងន់ធ្ងរពីអន្តរជាតិដោយពុំបានកែប្រែកំហុសទាំងនេះ។ ជាក់ស្តែង ប្រសិនបើរឿងក្តីនេះ ពុំមានការជ្រៀតជ្រែកខាងនយោបាយនោះទេ សាលាដំបូង គួរតែបានសម្រេចឲ្យជនជាប់ចោទទាំងពីររួចខ្លួន តាំងពីដំណាក់កាលដំបូងមកម្ល៉េះ អាស្រ័យដោយពុំមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ប្រឆាំងនឹងពួកគេ ដោយពុំចាំបាច់បារម្ភ ថាតើរដ្ឋាភិបាលទទួលយកសេចក្តីសម្រេចនោះបានឬក៏អត់នោះទេ។ ចៅក្រមស៊ើបសួរនៃរឿងក្តីដំបូងគេ បានសម្រេចលើកបណ្តឹងនោះចោលយ៉ាងក្លាហាន។ ពីរបីសប្តាហ៍ក្រោយមក គាត់ត្រូវបានផ្លាស់ទៅកាន់តុលាការខេត្តដាច់ស្រយាលមួយ ហើយសំណុំរឿងនោះ ត្រូវបានបញ្ជូនមកជំនុំជម្រះឡើងវិញ។

៤៦. ឧទាហរណ៍មួយទៀត ទាក់ទងនឹងរឿងក្តីប្រឆាំងមេធាវីនានា ដែលធ្វើការឲ្យមជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍(CLEC)។ នៅក្នុងខែមិថុនា ឆ្នាំ២០០៧ ពួកគេត្រូវបានដាក់ឲ្យស្ថិតក្រោមបណ្តឹងព្រហ្មទណ្ឌ ពីបទ "ញុះញង់" ប្រសិនបើពួកគេបន្តតំណាងឲ្យសហគមន៍ជនជាតិដើមភាគតិច មកពីភូមិកងយុ និងកងធំ ក្នុងខេត្តរតនៈគីរី ទាក់ទិននឹងបណ្តឹងដែលពួកគេបានប្តឹងប្រឆាំងពាណិជ្ជការិនីដ៏មានអំណាចម្នាក់ ពីបទរំលោភកម្មសិទ្ធិដីរបស់ជនជាតិដើមភាគតិច។ រឿងក្តីនោះ គឺជាការប៉ុនប៉ងដំបូងរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការប្រើប្រាស់តុលាការ ដើម្បីទទួលបានសំណង។ នៅក្នុងខែមិថុនា ឆ្នាំ២០០៧ ពាណិជ្ជការិនីម្នាក់នោះ បានដាក់បណ្តឹងព្រហ្មទណ្ឌប្រឆាំងនឹងតំណាងរបស់ភូមិទាំង១២ ដែលមេធាវីរបស់ពួកគេមកពីCLEC និងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា ព្រមទាំងតំណាងពីររូបនៃអង្គការមិនមែនរដ្ឋាភិបាលនានាប្រចាំខេត្តរតនៈគីរី។ អ្នកស្រីនោះបានស្នើឲ្យព្រះរាជអាជ្ញាខេត្តរតនៈគីរី ធ្វើការស៊ើបអង្កេតលើរឿងក្តីនោះ និងធ្វើបណ្តឹងពីបទឆបោក បទបរិហាកេរ្តិ៍ បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋដោយបានសំរេចផល និងបទញុះញង់ឲ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈឹមដោយពុំបានសំរេចផល។ ទោះបីជាចៅក្រមស៊ើបសួរនៃតុលាការខេត្តរតនៈគីរី បានលើកបណ្តឹងចោល កាលពីខែមីនា ឆ្នាំ២០០៩ ក៏ដោយ ក៏វាមានលក្ខណៈច្បាស់ក្រឡែត តាំងពីដំបូងទីមកហើយថា ពុំគួរនឹងមានការធ្វើបណ្តឹងពីបទញុះញង់នេះទាល់តែសោះ ពីព្រោះតែការញុះញង់ឲ្យជនណាម្នាក់ ទាមទារសិទ្ធិរបស់ខ្លួនតាមរយៈផ្លូវតុលាការ ពុំមែន និងពុំគួរក្លាយជាបទល្មើសនោះទេ ទោះជានៅក្រោមច្បាប់ណាក៏ដោយ។ លើសពីនេះទៅទៀត ពាណិជ្ជការិនីរូបនោះ ក៏បានដាក់ពាក្យបណ្តឹងទៅគណៈមេធាវីកម្ពុជា ប្រឆាំងនឹងមេធាវីទាំងប្រាំពីររូបរបស់ CLEC និងមេធាវីបីរូបរបស់អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។ លោកស្រីនោះបានចោទប្រកាន់ថា មេធាវីទាំងអស់នោះបានញុះញង់អ្នកភូមិ ឲ្យដាក់ពាក្យបណ្តឹងប្រឆាំងនឹងលោកស្រី ដោយលើកទឹកចិត្តពួកគេឲ្យបរិហាកេរ្តិ៍លោកស្រី និង

ផ្តល់ព័ត៌មានមិនពិតដល់សារព័ត៌មាន។ តាមដឹងមកថា គណៈមេធាវីបានបើកការស៊ើបសួរទាក់ទិននឹងមេធាវីទាំងដប់រូប ប៉ុន្តែក្រោយមកក៏ទម្លាក់ករណីចោល នៅពេលដែលគណៈមេធាវីទទួលរងការរិះគន់ពីសំណាក់អង្គការសិទ្ធិមនុស្សទាំងជាតិ និងអន្តរជាតិនានា។ ខណៈដែលទំនាស់ដីធ្លីពុំទាន់ត្រូវបានដោះស្រាយនៅឡើយ ក្រុមហ៊ុនរបស់លោកស្រីនោះ បានដំណើរការសកម្មភាពអភិវឌ្ឍន៍កសិកម្មរបស់ខ្លួន នៅលើដីនោះធ្វើព្រងើយ។

៤៧. មូលហេតុដែលបណ្តាលឲ្យអង្គតុលាការ ពុំទទួលបានកិត្តិយសដ៏សក្តិសមនោះ មានច្រើន។ មូលហេតុមួយចំនួន ផ្សាភ្ជាប់ទៅនឹងម័តកជាប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម។[5] កត្តាផ្សេងៗទៀតដែលរួមចំណែកចំពោះបញ្ហានេះ មាន៖

៤៨. ទីមួយ អវត្តមាននៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ដែលនឹងផ្តល់ឲ្យពួកគេ នូវកិច្ចការពារ សវុត្ថិភាពមុខតំណែង និងឯករាជភាពដែលពួកគេត្រូវការ ដើម្បីបំពេញការទទួលខុសត្រូវរបស់ពួកគេ ក្នុងលក្ខណៈឯករាជ្យ និងមានប្រសិទ្ធភាព។

៤៩. ទីពីរ អវត្តមាននៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ ហាក់ដូចជា មានផលប៉ះពាល់ដ៏មហន្តរាយលើប្រសិទ្ធភាព និងឯករាជភាពរបស់តុលាការ នៅក្នុងការផ្តល់យុត្តិធម៌ឲ្យទាន់ពេលវេលា សមស្រប និងឥតលំអៀង។ គេត្រូវការច្បាប់នេះជាចាំបាច់ ដើម្បីធ្វើឲ្យមានឯកភាព សិនិទ្ធពល និងភាពប្រាកដប្រជានៅក្នុងប្រព័ន្ធយុត្តិធម៌។ កម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ដែលជាផ្នែកមួយនៃ "យុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល" បានកំណត់អំពីការអនុម័តច្បាប់នេះ ប៉ុន្តែរហូតមកដល់ពេលនេះ មិនទាន់កើតចេញជារូបរាងនៅឡើយ។

៥០. ទីបី ភាគច្រើននៃចៅក្រម និងមេធាវី ជាពិសេសអ្នកជំនាន់មុន ហាក់ដូចជាពុំមានមូលដ្ឋានសមស្រប នៅក្នុងគោលការណ៍ទូទៅនៃនីតិរដ្ឋ និងបទដ្ឋានច្បាប់អន្តរជាតិនានា ដែលចៅក្រមនានា ត្រូវយល់ដឹងនោះទេ។ មានចំនួនអ្នកច្បាប់ជាន់ខ្ពស់តិចតួចប៉ុណ្ណោះនៅក្នុងប្រទេសនេះ។ ភាពពុំគ្រប់គ្រាន់នៃការអប់រំច្បាប់ និងការបណ្តុះបណ្តាលចៅក្រម និងព្រះរាជអាជ្ញា អំពីគោលការណ៍យុត្តិធម៌ជាមូលដ្ឋាននានា នីតិរដ្ឋ ព្រមទាំងបទដ្ឋានអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌ ជាកត្តារួមចំណែកធ្វើឲ្យតុលាការ ជាស្ថាប័នដ៏ខ្សោយមួយ នៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល។

៥១. ទីបួន ជាទូទៅប្រជាពលរដ្ឋហាក់ដូចជាភ័យខ្លាចចំពោះតុលាការ មួយផ្នែកដោយសារតែអំពើពុករលួយ និងមួយផ្នែកទៀតដោយសារលក្ខណៈដែលប្រព័ន្ធតុលាការកំពុងដំណើរការ។ ពុំមានមេធាវីការពារគ្រប់គ្រាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ ហើយការផ្តន្ទាទោសមានអាត្រាខ្ពស់ខ្លាំងណាស់។ នៅក្នុងរឿងក្តីភាគច្រើន ជនជាប់

[5] នៅសម័យខ្មែរក្រហម តុលាការត្រូវបានបំផ្លាញទាំងស្រុង ចៅក្រម និងមេធាវីភាគច្រើន ត្រូវបានគេសម្លាប់ រីឯសៀវភៅច្បាប់នានាត្រូវបានបំផ្លាញអស់។

ចោទ ត្រូវបានផ្តន្ទាទោសដោយតុលាការ ដោយផ្អែកលើចម្លើយសារភាព ដែលទទួលបានមកពីដំណាក់កាលឃាត់ខ្លួននៅនគរបាល ដែលជានិច្ចកាលធ្វើឡើងក្រោមការបង្ខិតបង្ខំ។ មានប្រជាពលរដ្ឋមួយចំនួនធំ ដែលបានពាក់ព័ន្ធនឹងទំនាស់ដីធ្លី ប៉ុន្តែដោយសារតែទំនាស់បែបនោះ គឺជាករណីរដ្ឋប្បវេណី ពុំមានការផ្តល់ជំនួយផ្នែកច្បាប់ពីរដ្ឋសូម្បីតែសម្រាប់ជនក្រីក្រនោះឡើយ។ ពុំមាននគរបាលជាស្ត្រីគ្រប់គ្រាន់ដើម្បីធ្វើការស៊ើបអង្កេតលើបទល្មើសប្រឆាំងនឹងស្ត្រី។ ពុំមានការផ្តល់ការបណ្តុះបណ្តាលសមស្រប នៅក្នុងវិទ្យាសាស្ត្រខាងកោសលវិច្ច័យសម្រាប់នគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរនានា។ ពុំមានការបែងចែកឲ្យច្បាស់រវាងព្រះរាជអាជ្ញា និងចៅក្រមនានា ហើយប្រជាពលរដ្ឋកម្ពុជា មានការលំបាកក្នុងការយល់ដឹងអំពីតួនាទីរៀងៗខ្លួនរបស់ពួកគេ។

៥២. ទីប្រាំ អំពើពុករលួយហាក់ដូចជាសាយភាយនៅគ្រប់កម្រិតទាំងអស់នៃប្រព័ន្ធតុលាការ។ ពីព្រោះតែពុំមានច្បាប់ដែលត្រូវការសម្រាប់ការពារចៅក្រម ធ្វើឲ្យចៅក្រមត្រូវបានចាត់ទុកថាជាមន្ត្រីរាជការស៊ីវិល ហើយហាក់ដូចជាពឹងផ្អែកទៅលើបរិបាលកិច្ច និងការការពារខាងនយោបាយជាជាងពឹងផ្អែកលើច្បាប់សម្រាប់សុវត្ថិភាពនៃការងាររបស់ពួកគេ។ បញ្ហានេះបណ្តាលឲ្យប៉ះពាល់ដល់ឯករាជ្យភាពបុគ្គលចៅក្រម និងព្រះរាជអាជ្ញានានា។

៥៣. ទីប្រាំមួយ នីតិវិធីតុលាការត្រូវបានប្រើប្រាស់ដោយអ្នកមានប្រាក់ និងអំណាច នៅក្នុងរឿងក្តីជាច្រើន ដើម្បីដកហូត យាយី និងបំភិតបំភ័យអ្នកក្រីក្រ ក៏ដូចជាមេធាវីរបស់ពួកគេ និងអ្នកទាំងឡាយណា ដែលធ្វើការសម្រាប់ពួកគេ នៅក្នុងវិស័យសង្គមស៊ីវិល។

៥៤. ទីប្រាំពីរ កង្វះនៃធនធានមនុស្ស ធនធានថវិកា និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ហាក់ដូចជាធ្វើឲ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការងាររបស់ប្រព័ន្ធតុលាការ។ ជាកាលប្បវត្តិ ប្រព័ន្ធតុលាការនៅកម្ពុជា ពុំមានថវិកា ធនធាន និងបុគ្គលិកគ្រប់គ្រាន់ ដើម្បីដំណើរការឲ្យបានត្រឹមត្រូវនោះទេ។ ព្រះរាជអាជ្ញា ពុំមានមូលនិធិគ្រប់គ្រាន់ ដើម្បីបង្គាប់ឲ្យមានការស៊ើបអង្កេតបែបវិទ្យាសាស្ត្របានត្រឹមត្រូវលើបទល្មើសព្រហ្មទណ្ឌនានាទេ។ ដូច្នោះហើយ ទើបមាននិន្នាការពឹងផ្អែកទៅលើចម្លើយសារភាព ដែលនគរបាលយុត្តិធម៌ ទទួលបានពីជនជាប់ចោទ។ នគរបាលយុត្តិធម៌ផ្ទាល់ ក៏ពុំទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ នៅក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌនោះទេ ហើយជានិច្ចកាល តែងតែប្រើប្រាស់ការបង្ខិតបង្ខំឬកម្លាំង ដើម្បីទទួលបានចម្លើយសារភាពនៃពិរុទ្ធភាព។

៥៥. ទីប្រាំបី ចំនួននៃមេធាវី និងចៅក្រមមានកម្រិតទាបខ្លាំងណាស់ បើប្រៀបធៀបទៅនឹងចំនួន នៃប្រជាពលរដ្ឋកម្ពុជា។ បញ្ហានេះ គឺជាកង្វល់ដ៏ធ្ងន់ធ្ងរមួយនៅក្នុងប្រព័ន្ធតុលាការ ព្រោះបើពុំមានមេធាវីការពារនោះពុំមានអ្នកណាម្នាក់អាចចូលទៅសិក្សាលើសំណុំរឿងរបស់តុលាការបាននោះទេ។ ជាងនេះទៅទៀតនោះ គឺថា សាលក្រមភាគច្រើនត្រូវបានចាត់ទុកថាជាការសម្ងាត់។ មានតែសាលាឧទ្ធរណ៍តែមួយគត់នៅរាជធានីភ្នំពេញ រីឯជនក្រីក្រពុំអាចមានលទ្ធភាពធ្វើដំណើរ មកកាន់រាជធានីដើម្បីស្វែងរកយុត្តិធម៌នោះទេ។ សូម្បីតែអង្គភាព

មធ្យោបាយរបស់រដ្ឋ ក៏ហាក់ដូចជាពុំមានថវិកាគ្រប់គ្រាន់ក្នុងការបញ្ជូនជនជាប់ឃុំមកជំនុំជម្រះនៅសាលាឧទ្ធរណ៍ក្នុងរាជធានីភ្នំពេញដែរ។ ជាលទ្ធផល សវនាការសាលាឧទ្ធរណ៍ភាគច្រើន បានប្រព្រឹត្តទៅដោយពុំមានវត្តមាននៃជនជាប់ចោទ ឬសូម្បីតែមេធាវីរបស់ពួកគេ។

៥៦. ដំណើរការនៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ គឺជាដំណើរការបន្តរហូត ទោះជានៅក្នុងប្រទេសណាក៏ដោយ។ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើឲ្យប្រសើរឡើងគួរកត់សំគាល់នូវការទទួលបានព័ត៌មានច្បាប់ និងតុលាការ ហើយកម្មវិធីផ្សេងៗជាច្រើនទៀត កំពុងត្រូវបានអនុវត្តដើម្បីធ្វើឲ្យប្រសើរឡើងដល់ប្រព័ន្ធនេះ តាមរយៈមធ្យោបាយផ្សេងៗ ដូចជាការបោះផ្សាយអត្ថបទច្បាប់ និងដីកាសម្រេចនានារបស់តុលាការជាដើម។ ការប្រព្រឹត្តទៅនៃប្រព័ន្ធតុលាការ ត្រូវបានធ្វើឲ្យប្រសើរឡើង តាមរយៈកម្មវិធីពន្លឿនការបណ្តុះបណ្តាលបែបអន្តរកម្ម ហើយនិងការអនុវត្តន៍គម្រោងតុលាការគំរូ ការកសាង និងជួសជុលអគារតុលាការ ការបង្កើតមណ្ឌលយុត្តិធម៌សម្រាប់សេវាផ្នែកច្បាប់នៅថ្នាក់ស្រុកនិងការបង្កើតនូវយន្តការផ្សេងៗ ដូចជាតុលាការការងារសម្រាប់ដោះស្រាយវិវាទការងារនានា។

៥៧. ការអប់រំផ្នែកនីតិសាស្ត្រ ទទួលបានកំណែទម្រង់ជាដុំកំភួន ក្នុងរយៈពេល១៥ឆ្នាំកន្លងមកនេះ ក្រោមកិច្ចឧបត្ថម្ភដ៏ធំធេងពីរដ្ឋាភិបាលបារាំង ក្នុងការបណ្តុះបណ្តាលនិស្សិតច្បាប់នានា ការតាក់តែងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ព្រមទាំងការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ពីរដ្ឋាភិបាលជប៉ុនក្នុងការតាក់តែងក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីថ្មី និងក្នុងការគាំទ្រដល់ការបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី ហើយនិងពីរដ្ឋាភិបាលអូស្ត្រាលី តាមរយៈគម្រោងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា ដែលផ្តោតការយកចិត្តទុកដាក់ទៅលើការបង្ការបទល្មើស សុវត្ថិភាពសហគមន៍ កំណែទម្រង់តុលាការ និងមណ្ឌលអប់រំកែប្រែ និងការបណ្តុះបណ្តាលនគរបាល។ នៅក្នុងឆ្នាំ២០០៥ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បានដាក់បញ្ចូលការបណ្តុះបណ្តាលក្រឡាបញ្ជី ព្រះរាជអាជ្ញា និងអាជ្ញាសាលា។ ការបង្កើតនរាជបណ្ឌិតសភានេះ គឺជាកត្តាគន្លឹះមួយក្នុងការធ្វើឲ្យប្រសើរឡើងនូវការបណ្តុះបណ្តាលវិជ្ជាជីវៈចៅក្រម និងព្រះរាជអាជ្ញា។ បញ្ហាជារចនាសម្ព័ន្ធផ្សេងៗទៀត នឹងត្រូវបានលើកយកទៅដោះស្រាយ ដោយស្ថាប័នកំពូលទាំងបីរបស់រដ្ឋ ហើយអង្គនីតិប្រតិបត្តិ ត្រូវការដាក់កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជាអាទិភាព ដើម្បីផ្តល់យុត្តិធម៌ដែលកំពុងត្រូវការជាទីបំផុត និងរង់ចាំជាយូរណាស់មកហើយ ដល់ប្រជាពលរដ្ឋកម្ពុជាទូទៅ។

**អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា**

៥៨. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ECCC) គឺជាតុលាការកម្ពុជា ដែលមានការចូលរួមនៃចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិ។ បន្ទាប់ពីការចាប់ផ្តើមដ៏យឺតយ៉ាវគួរសម ECCC ទទួលបានជោគជ័យគួរឲ្យកត់សំគាល់ និងបានបញ្ចប់ការជំនុំជម្រះសំណុំរឿងទីមួយរបស់ខ្លួន។ សវនាការជំនុំជម្រះកាំង ហ្គេកអ៊ាវ ហៅ

ឌុច" ដែលជាលេខាគណៈកម្មាធិការមន្ទីរសន្តិបាល ស-២១ របស់របបខ្មែរក្រហម បានបញ្ចប់នៅក្នុងខែវិច្ឆិកា ឆ្នាំ ២០០៩។ អង្គជំនុំជម្រះនេះបានចេញសាលក្រមនៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ផ្តន្ទាទោសនិងដាក់ពន្ធនាគារ ឌុច រយៈពេល ៣៥ឆ្នាំ។ សវនាការនានានៅអង្គជំនុំជម្រះនេះ បានបង្ហាញដល់សហគមន៍ជាតិ និងអន្តរជាតិថា ECCC មានសមត្ថភាពបើកសវនាការជំនុំជម្រះរឿងក្តីព្រហ្មទណ្ឌដ៏ស្មុគស្មាញ អនុលោមតាមបទដ្ឋានអន្តរជាតិ ហើយការងារនៃអង្គជំនុំជម្រះវិសាមញ្ញនេះ គឺទំនងជានឹងត្រូវចាត់ទុកជាគំរូល្អ សម្រាប់ប្រព័ន្ធតុលាការកម្ពុជា។ ការងារនៃអង្គជំនុំជម្រះនេះ បានទាក់ទាញការចាប់អារម្មណ៍ដ៏លើសលប់ពីសាធារណៈជន។ ប្រជាជនជាង ៣១,០០០នាក់ មកពីគ្រប់ទីកន្លែងនៅកម្ពុជា បានចូលទស្សនកិច្ចអង្គជំនុំជម្រះនេះ ដើម្បីតាមដានសវនាការ។ គេរំពឹងទុកថា សវនាការនៃសំណុំរឿងបន្ទាប់ នឹងចាប់ផ្តើមនាសទរដូវនេះ។ មានភាពប្រាកដប្រជាថា សំណុំរឿងបន្តបន្ទាប់ទៀត នឹងចាប់ដំណើរការ ខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ខ្លួនប្រឆាំងនឹងបុគ្គលប្រាំរូបបន្ថែមទៀតរួចរាល់ហើយ។

៥៩. ក្រៅពីអង្គការមិនមែនរដ្ឋាភិបាលនានា ដូចជាអង្គការផ្តួចផ្តើមយុត្តិធម៌អន្តរជាតិអាស៊ី និងអង្គការផ្តួចផ្តើមយុត្តិធម៌សង្គមបើកចំហ ពុំមានអង្គការសហប្រជាជាតិ ឬយន្តការអន្តរជាតិផ្លូវការផ្សេងៗទៀត តាមឃ្លាំមើលសកម្មភាពនានារបស់ ECCC ការពារឯករាជ្យភាព និងបូរណភាពរបស់ស្ថាប័ននេះ ក៏ដូចជាជូនដំណឹងដល់សហគមន៍ជាតិ និងអន្តរជាតិ អំពីសមិទ្ធផលទទួលបាន និងការប្រឈមនានាដែលតុលាការនេះ កំពុងជួបប្រទះនោះទេ។ មានការរំពឹងទុកយ៉ាងខ្ពស់ថា ECCC នឹងដើរតួជាតុលាការគំរូមួយនៅកម្ពុជា ដើម្បីឲ្យការអនុវត្តន៍ល្អៗ អាចត្រូវយកទៅចែករំលែកជាមួយប្រព័ន្ធតុលាការកម្ពុជាទាំងមូល ហើយជាសន្ទឹមៗ នឹងលើកដំកើងការអនុវត្តន៍របស់តុលាការនេះ។ វត្តមានរបស់ ECCC នៅក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ផ្តល់លទ្ធភាពជាសក្តានុពលឲ្យចៅក្រមព្រះរាជអាជ្ញានិងមន្ត្រីតុលាការផ្សេងៗទៀតរបស់កម្ពុជានៅឯECCC ធ្វើការផ្ទេរចំណេះដឹងទៅដល់សហការីរបស់ពួកគេនៅក្នុងប្រព័ន្ធតុលាការជាតិ។ គម្រោងបែបនេះ កំពុងត្រូវបានផ្តួចផ្តើមដោយការិយាល័យ OHCHR ប្រចាំកម្ពុជា និងដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និតជាមួយចៅក្រម និងព្រះរាជអាជ្ញានានារបស់កម្ពុជា។

៦០. ផែនការនៃការចូលរួមរបស់ជនរងគ្រោះជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានបង្កើតឡើងនៅក្នុងប្រព័ន្ធ ECCC ហាក់ដូចជាបានផ្តល់ការរួមចំណែកជាវិជ្ជមានដល់សង្គម ក្នុងការផ្សះផ្សារជាមួយនឹងអតីតដ៏សោកនាដកម្មរបស់ខ្លួន និងក្នុងការព្យាបាលដំបៅផ្លូវចិត្តរបស់ប្រជាជនកម្ពុជា។ កម្មវិធីទស្សនកិច្ច តាមការរៀបចំទៅកាន់ECCC សម្រាប់ប្រជាពលរដ្ឋកម្ពុជាសាមញ្ញ ហាក់ដូចជាបានបម្រើជាឧបករណ៍អប់រំមួយនៅក្នុងប្រទេសនេះ ក្នុងការលើកកំពស់ដល់គំនិតនៃការជំនុំជម្រះដោយយុត្តិធម៌ និងនីតិរដ្ឋ។ សរុបមក ពិសោធន៍ថ្មីៗ នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិនេះ ហាក់ដូចជាបានដំណើរការទៅយ៉ាងល្អគួរសម មកទល់ត្រឹមនេះ។

៦១. អ្នករាយការណ៍ពិសេស បានស្វាគមន៍សាលក្រមដែលECCCបានចេញ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ លើសំណុំរឿងរបស់កាំង ហ្កេកអ៊ាវ។ ទោះបីជាការផ្តន្ទាទោសគាត់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្រ្គាម ប្រព្រឹត្តទៅក្រោយអំពើឧក្រិដ្ឋនោះជាងបីទសវត្សរ៍ក៏ដោយ ក៏សាលក្រមនោះ បានបញ្ជាក់ អំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការនាំយកមកជំនុំជម្រះនូវបទឧក្រិដ្ឋនានា ដែលត្រូវបានប្រព្រឹត្ត នៅកំឡុងរបបខ្មែរក្រហម ដោយអនុលោមតាមបទដ្ឋានទទួលស្គាល់ជាអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌ ដែលជាដំណើរការជំនុំជម្រះក្តីពុំធ្លាប់មានពីមុនមកនៅកម្ពុជា។

៦២. អ្នករាយការណ៍ពិសេស សង្ឃឹមថា ការជំនុំជម្រះនេះ នឹងមានផលប៉ះពាល់ជាវិជ្ជមានដល់ការ ពង្រឹងឯករាជ្យភាពប្រព័ន្ធតុលាការ។ លោកបានស្វាគមន៍ ការបញ្ចប់នៃសំណុំរឿងទីមួយនេះ ហើយបានលើកទឹក ចិត្តឲ្យគ្រប់ភាគីទាំងអស់ ធ្វើការជាមួយគ្នា ដើម្បីឆ្ពោះទៅបញ្ចប់សំណុំរឿងបីដែលនៅសល់បន្តទៀត។ លោកបាន ជំរុញឲ្យចៅក្រមនានានៃអង្គជំនុំជម្រះក្នុងតុលាការកម្ពុជា ខំប្រឹងពង្រឹងឯករាជ្យភាព និងបូរណភាពរបស់ខ្លួន និង លើកកំពស់បទដ្ឋានយុត្តិធម៌ឲ្យបានខ្ពស់បំផុត ព្រមទាំងបន្តបង្ហាញដោយឧទាហរណ៍ ដល់ប្រព័ន្ធតុលាការជាតិ និងប្រជាពលរដ្ឋ។ អ្នករាយការណ៍ពិសេស សង្ឃឹមថា សាលក្រមដ៏មានសារសំខាន់នេះ នឹងដើរតួជាចលករមួយ មួយ ដើម្បីឲ្យរដ្ឋាភិបាលដោះស្រាយចំពោះបញ្ហានិទណ្ឌភាព ហើយពន្លឿនកំណែទម្រង់ច្បាប់ និងតុលាការ។

៦៣. សហគមន៍អន្តរជាតិ គួរតែបន្តផ្តល់ការគាំទ្រដល់តំរូវការរបស់ECCC ក្នុងដំណើរការស៊ើបអង្កេត និងជំនុំជម្រះ ឲ្យស្របតាមបទដ្ឋានអន្តរជាតិនានា និងក្នុងការធានាថា ប្រព័ន្ធតុលាការជាតិទាំងមូល នឹងទទួល បានប្រយោជន៍ពីការងាររបស់អង្គជំនុំជម្រះវិសាមញ្ញនេះ។

## ៧. សេចក្តីសន្និដ្ឋាន

៦៤. កម្ពុជាបានបោះជំហានទៅមុខយ៉ាងលឿនក្នុងការពង្រឹងសិទ្ធិមនុស្សនៅប៉ុន្មានឆ្នាំថ្មីៗនេះ ក្រោម បរិយាកាសនៃស្ថេរភាពនយោបាយ កំណើនសេដ្ឋកិច្ច ព្រមទាំងជំនួយ និងការគាំទ្រដ៏សប្បុរសជាបន្តរបស់ សហគមន៍អន្តរជាតិ។ ការប្រឈមសម្រាប់រដ្ឋាភិបាលជាបឋមបំផុត គឺត្រូវអនុវត្តច្បាប់នានារបស់កម្ពុជា ឲ្យមាន ប្រសិទ្ធភាពបំផុត។ នៅក្នុងដំណើរការនេះ រដ្ឋាភិបាលកម្ពុជា មិនគ្រាន់តែត្រូវការបំប្លែងកាតព្វកិច្ចសិទ្ធិមនុស្សអន្តរ ជាតិនានារបស់ខ្លួន ឲ្យទៅជាច្បាប់ជាតិនោះទេ ប៉ុន្តែត្រូវយកច្បាប់ទាំងនេះទៅអនុវត្ត ដើម្បីពង្រឹងវប្បធម៌ពហុភាគី និងការអត់ធ្មត់ ព្រមទាំងធ្វើដំណើរឆ្ពោះទៅរកដំណើរការធ្វើសេចក្តីសម្រេចចិត្តមួយ ដែលបើកទូលាយ ឲ្យមាន ការចូលរួម និងតម្លាភាពលើបញ្ហានានា ដែលមានផលប៉ះពាល់ដោយផ្ទាល់លើសិទ្ធិរបស់ប្រជាពលរដ្ឋ។ នៅក្នុង វិស័យទាំងនេះ ដែលនឹងតម្រូវឲ្យមានកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការប្រកបដោយអត្ថន័យ និងការស្ថាបនា ក្នុងចំណោមរដ្ឋាភិបាល សង្គមស៊ីវិល និងសហគមន៍អន្តរជាតិ។ កិច្ចសន្ទនារវាងរដ្ឋ និងសង្គមស៊ីវិល មានសារ-

សំខាន់ខ្លាំងណាស់ សម្រាប់រដ្ឋទាំងឡាយ នៅគ្រប់ដំណាក់កាលទាំងអស់នៃការអភិវឌ្ឍន៍ ហើយជាពិសេស នៅក្នុងប្រទេសដូចជាកម្ពុជាដែលកំពុងតែក្រោកឡើងវិញពីសង្គ្រាម និងកំពុងស្ថិតនៅក្នុងដំណាក់កាលអន្តរកាលនៅឡើយ។ រដ្ឋាភិបាល បានដំណើរការទៅមុខយ៉ាងល្អប្រសើរ ក្នុងការលើកកំពស់ និងការពារសិទ្ធិមនុស្ស នៅក្នុងប្រទេសនេះ ប៉ុន្តែនៅសល់កិច្ចការជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីបំពេញតាមបទដ្ឋានអន្តរជាតិនៅក្នុងវិស័យសិទ្ធិមនុស្សនេះ។

៦៥. អ្នករាយការណ៍ពិសេស មានក្តីសោមនស្សរីករាយដោយកត់សំគាល់ឃើញថា រដ្ឋាភិបាលហាក់ដូចជាមានបំណងចិត្ត និងឆន្ទៈនយោបាយក្នុងការធ្វើកំណែទម្រង់វិស័យច្បាប់និងប្រព័ន្ធយុត្តិធម៌។ អ្នករាយការណ៍ពិសេសមានក្តីសោមនស្ស និងឯកសិទ្ធិដ៏ខ្ពង់ខ្ពស់ដែលបានធ្វើការជាមួយនាយករដ្ឋមន្ត្រីកម្ពុជា សមាជិកជាន់ខ្ពស់នានារបស់រដ្ឋ និងសង្គមស៊ីវិល ហើយលោកត្រៀមខ្លួនជាស្រេចដើម្បីបន្តធ្វើការជាមួយអ្នកពាក់ព័ន្ធទាំងនេះ ក្នុងការនាំមកនូវកំណែទម្រង់ជារូបវន្ត ដល់ប្រព័ន្ធតុលាការកម្ពុជា។ អាស្រ័យហេតុនេះហើយ អ្នករាយការណ៍ពិសេសសូមលើកទឹកចិត្តដល់រដ្ឋាភិបាល ឲ្យបន្តធ្វើការលើរបៀបវារៈនៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់ខ្លួនដោយកសាង លើសមិទ្ធផលដែលសម្រេចបានរួចហើយ ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្សនៅកម្ពុជា។

## ៨. អនុសាសន៍

### ជំហានក្នុងការធ្វើឲ្យប្រសើរឡើងដល់ឯករាជ្យភាពនៃប្រព័ន្ធតុលាការ

៦៦. *កម្ពុជាគួរតែអនុម័ត និងដាក់ឲ្យចូលជាធរមាននូវច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃតុលាការ ដោយគ្មានការពន្យាពេល។ ច្បាប់ទាំងនេះ គួរតែត្រូវបានបង្កើតឡើង ដើម្បីធានាឯករាជ្យភាពទាំងស្ថាប័ន និងបុគ្គលនានា នៅក្នុងប្រព័ន្ធតុលាការ ក៏ដូចជាចាត់វិធានការខាងវិន័យប្រឆាំងនឹងការប្រព្រឹត្តមិនត្រឹមត្រូវនានារបស់តុលាការ និងចៅក្រមពុករលួយ និងអសមត្ថភាពនានា។ រដ្ឋធម្មនុញ្ញ តម្រូវឲ្យអនុម័តច្បាប់ទាំងនេះ ដែលអវត្តមាន អស់រយៈពេលជាង១៧ឆ្នាំមកហើយ។ ច្បាប់ទាំងនេះ នឹងរួមចំណែកការពារមុខតំណែងរបស់ចៅក្រម និងការពារលក្ខខណ្ឌនៃការងាររបស់ពួកគេ ដោយផ្អែកលើក្រមសីលធម៌សម្រាប់ចៅក្រមនិងព្រះរាជអាជ្ញា។*

៦៧. *ច្បាប់ថ្មីទាំងនេះ គួរតែហាមឃាត់សមាជិកសកម្មនៃគណៈបក្សនយោបាយនានា មិនឲ្យកាន់តំណែងនានាក្នុងវិស័យតុលាការ ព្រមទាំងហាមឃាត់ចៅក្រម និងព្រះរាជអាជ្ញានានា មិនឲ្យបំពេញមុខងារជាទីប្រឹក្សានានារបស់អ្នកដឹកនាំនយោបាយ ឬរដ្ឋមន្ត្រីនានា។ ចៅក្រម និងព្រះរាជអាជ្ញានានា*

អាចជាសមាជិកនៃគណៈបក្សនយោបាយណាមួយ មុនពេលការតែងតាំងរបស់ខ្លួន។ យ៉ាងណាមិញ នៅពេលដែលពួកគេត្រូវបានតែងតាំងទៅកាន់តំណែងនានាក្នុងវិស័យតុលាការ ពួកគេគួរតែបញ្ចប់មុខងារជាសមាជិកសកម្មក្នុងគណៈបក្សនយោបាយណាមួយនោះ ឬឈប់ដើរតួនាទីណាមួយ នៅក្នុងសកម្មភាពនានារបស់គណៈបក្សនយោបាយណាមួយនោះតទៅទៀត។

៦៨. ចៅក្រម និងព្រះរាជអាជ្ញានានា គួរតែទទួលកម្រៃតបស្នងគ្រប់គ្រាន់ តម្រូវឲ្យធ្វើការពេញម៉ោង និងហាមឃាត់មិនឲ្យបំពេញមុខងារក្រៅវិស័យតុលាការ។ ចៅក្រម និងព្រះរាជអាជ្ញា គួរតែទទួលបានប្រាក់ខែ និងប្រាក់ឧបត្ថម្ភផ្សេងៗទៀតមកពីប្រភពតែមួយគត់ ឧទាហរណ៍៖ មកពីក្រសួងយុត្តិធម៌។ នាពេលបច្ចុប្បន្ន ចៅក្រមទទួលបានប្រាក់ខែពីក្រសួងយុត្តិធម៌ និងប្រាក់បំណាច់មុខងារដោយឡែកពីគណៈរដ្ឋមន្ត្រី។ ការអនុវត្តន៍បែបនេះ ពុំអាចធ្វើឲ្យតុលាការឯករាជ ចេញពីអង្គនីតិប្រតិបត្តិនោះទេ។

៦៩. តុលាការកំពូល គួរមានការទទួលខុសត្រូវទាំងមូល ចំពោះការគ្រប់គ្រងតុលាការជាន់ទាបនានា គឺមិនមែនជាក្រសួងយុត្តិធម៌នោះទេ។

៧០. ព្រះរាជអាជ្ញា ពុំគួរស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌នោះទេ ប៉ុន្តែគួរស្ថិតក្រោមឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

៧១. គួរតែមានការិយាល័យដាច់ដោយឡែក និងឯករាជមួយសម្រាប់អគ្គព្រះរាជអាជ្ញា ដែលមានអំណាចគ្រប់គ្រងលើព្រះរាជអាជ្ញានៅគ្រប់ជាន់ថ្នាក់ ហើយព្រះរាជអាជ្ញាទាំងអស់ គួរស្ថិតក្រោមការិយាល័យឯករាជមួយ ជាជាងនៅអមតុលាការសាមីនានា។

## កំណែទម្រង់នៃសមាសសតាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

៧២. ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម (SCM) គួរធ្វើវិសោធនកម្ម ដើម្បីធ្វើឲ្យស្ថាប័ននេះ មានឯករាជ្យភាពយ៉ាងពិតប្រាកដ។ ច្បាប់ជាធរមាន ទទួលស្គាល់រួចទៅហើយនូវគោលការណ៍ដែលថា សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម អាចជាចៅក្រម និងព្រះរាជអាជ្ញានានា ដែលត្រូវបានបោះឆ្នោតជ្រើសរើស ដោយសហការីរបស់ពួកគេ ពីក្នុងរង្វង់ចំនួនរបស់ពួកគេ។ គោលការណ៍នេះ គួរតែមានវិសាលភាពអនុញ្ញាតឲ្យសមាជិកទាំងអស់ (លើកលែងតែព្រះមហាក្សត្រ) ត្រូវបានការបោះឆ្នោតជ្រើសរើសពីក្នុងចំណោមឥស្សរៈជនជាន់ខ្ពស់បំផុត នៅក្នុង

ប្រព័ន្ធតុលាការ ពីចៅក្រមជាន់ខ្ពស់ដែលចូលនិវត្តន៍ ឬពីក្នុងចំណោមសាស្ត្រាចារ្យច្បាប់ល្បីល្បាញនានា។ ធ្វើដូច្នោះបាន នឹងពង្រឹងឯករាជ្យភាពនៃប្រព័ន្ធតុលាការ ដោយដកចេញនូវការគ្រប់គ្រងបច្ចុប្បន្នរបស់អង្គនីតិប្រតិបត្តិ ហើយនឹងបង្កើតនូវនីតិវិធីបែបប្រជាធិបតេយ្យ និងប្រកបដោយតម្លាភាពមួយ ក្នុងការជ្រើសរើស និងការតែងតាំងសមាជិកនានា។ បីរូបក្នុងចំណោមសមាជិកទាំងប្រាំបួនរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តម្រូវឲ្យបោះឆ្នោតជ្រើសរើសដោយចៅក្រមនានា។ ប៉ុន្តែទោះបីជាដូច្នោះក៏ដោយ ការបោះឆ្នោតជ្រើសរើសនោះ មិនដែលកើតមានឡើយ ហើយអង្គនីតិប្រតិបត្តិ បាននឹងកំពុងធ្វើការតែងតាំងបែបនោះទៅវិញ។ ដូច្នេះ វាសមហេតុផលណាស់ ដែលគេត្រូវសួរដេញដោលពីសមាសភាពបច្ចុប្បន្នរបស់ឧត្តមក្រុមប្រឹក្សានេះ។ លើសពីនេះទៅទៀត សមាសភាពបច្ចុប្បន្នជាពិសេសវត្តមាននៃសមាជិក៦រូប ដែលបានក្លាយជាសមាជិកតាមរយៈមុខតំណែង ក្នុងចំណោម៩រូប ពុំបានជួយឲ្យក្រុមប្រឹក្សានេះ ប្រព្រឹត្តទៅ ដោយមានប្រសិទ្ធភាព និងឯករាជនោះទេ។ ក៏ដូចគ្នានេះផងដែរ គ្មានបទប្បញ្ញត្តិនៃការតែងតាំងប្រធានសាលាឧទ្ធរណ៍ ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍នោះទេ។ នេះដោយសារតែមន្ត្រីតុលាការថ្នាក់កណ្តាលទាំងនេះ អាចធ្វើការសម្រេចចិត្ត ទាក់ទិននឹងការតែងតាំងចៅក្រមនានានៃតុលាការជាន់ខ្ពស់ ឧទាហរណ៍ តុលាការកំពូល ឬក៏ចាត់វិធានការវិន័យប្រឆាំងនឹងសមាជិកនៃតុលាការ ដែលមានឋានៈខ្ពស់ជាងពួកគេ។ ស្ថានការណ៍នេះ ដាក់ប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងស្ថានភាពមិនសមប្រកបមួយ ហើយអាចបណ្តាលឲ្យប្រសិទ្ធភាព និងឯករាជ្យភាពរបស់ពួកគេ ធ្លាក់ចុះ។

៧៣. សមាជិកនានារបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែឈប់បំពេញមុខងារ ជាចៅក្រមសកម្ម កំឡុងពេលដែលពួកគេកំពុងបម្រើការជាសមាជិកនៃឧត្តមក្រុមប្រឹក្សា ហើយពុំគួរធ្វើជាសមាជិកនៃគណៈបក្សនយោបាយណាមួយនោះឡើយ។ មានហេតុផលបី ដែលធ្វើឲ្យសំណើបែបនេះ សមហេតុសមផល។ ទីមួយ វាកាត់បន្ថយទំនាស់នៃផលប្រយោជន៍ជាសក្តានុពល រវាងភារកិច្ចនានានៃសមាជិករបស់ឧត្តមក្រុមប្រឹក្សា និងសកម្មភាពនានារបស់ចៅក្រមសកម្មក្នុងតុលាការ។ ទីពីរ វាផ្តល់លទ្ធភាពឲ្យសមាជិកនានានៃស្ថាប័ននេះ ផ្តោតពេលវេលាពេញម៉ោងរបស់ពួកគេ ទៅលើការទទួលខុសត្រូវនានារបស់ឧត្តមក្រុមប្រឹក្សា ដោយពុំរំខានដល់ការងារតុលាការជាប្រក្រតីរបស់ពួកគាត់។ សមាជិករបស់ឧត្តមក្រុមប្រឹក្សា គួរត្រូវបានផ្តល់តំណែងឲ្យក្នុងអាណត្តិជាក់លាក់មួយ ដែលអាចបន្តជាថ្មីបានម្តង ហើយសម្រាប់រយៈពេលនៃតំណែងក្នុងឧត្តមក្រុមប្រឹក្សានេះ សមាជិកទាំងឡាយ គួរតែស្ថិត

នៅក្រៅក្របខណ្ឌនៃប្រព័ន្ធតុលាការ។ ទីបី ពួកគេ នឹងមានលទ្ធភាពបំពេញការទទួលខុសត្រូវរបស់ខ្លួនបានត្រឹមត្រូវ និងឯករាជ ព្រមទាំងក្នុងលក្ខណៈមិនប្រកាន់បក្សសម្ព័ន្ធមួយ។

៧៤. តំណែងមួយចំនួននៅឧត្តមក្រុមប្រឹក្សានេះ គួរតែបំរុងទុកសម្រាប់ស្ត្រី។ សំណើនេះ អនុលោមតាមការទទួលខុសត្រូវរបស់កម្ពុជា ក្រោមអនុសញ្ញាស្តីពីការលប់បំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងស្ត្រីភេទ។ បន្ថែមលើនេះទៀត ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែចែងអំពីភារកិច្ចជាក់លាក់មួយ សំរាប់ក្រុមប្រឹក្សានេះ ដើម្បីលើកស្ទួយការតែងតាំង និងការតំណើងឋានន្តរសក្តិដល់ចៅក្រម និងព្រះរាជអាជ្ញាជាស្ត្រី ដែលមានសមត្ថភាព និងស្នាដៃ។

**កំណែទម្រង់លេខាធិការដ្ឋានរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម**

៧៥. ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែមានលេខាធិការដ្ឋានផ្ទាល់របស់ខ្លួន និងដឹកនាំដោយចៅក្រមជាន់ខ្ពស់មួយរូប ដែលត្រូវបានតែងតាំងដោយព្រះមហាក្សត្រ ឬដោយក្រុមប្រឹក្សានេះផ្ទាល់ គឺមិនមែនតែងតាំងដោយក្រសួងយុត្តិធម៌នោះទេ។ កំណែទម្រង់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គួរតែរួមបញ្ចូលនូវលេខាធិការដ្ឋានដែលមានវិជ្ជាជីវៈមួយ ក្រោមការគ្រប់គ្រងដោយផ្ទាល់ពីសមាជិកនានានៃឧត្តមក្រុមប្រឹក្សានេះ។ លេខាធិការដ្ឋានដ៏រឹងមាំមួយ បូករួមនឹងសមាជិកដែលបំពេញមុខងារពេញម៉ោង នឹងបង្កើនសមត្ថភាពការងាររបស់ក្រុមប្រឹក្សានេះ ហើយក្រុមជំនួយការដែលបានបង្កើតក្នុងឆ្នាំ២០០៩នោះ ត្រូវបានរំសាយចោល។

**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ផ្សេងទៀត**

៧៦. សមត្ថភាពរបស់សាលាឧទ្ធរណ៍ គួរតែត្រូវបានធ្វើឲ្យប្រសើរឡើងយ៉ាងប្រាកដប្រជា ដើម្បីផ្តល់លទ្ធភាពឲ្យស្ថាប័ននេះ ដោះស្រាយលើសំណុំរឿងដែលកកស្ទះយ៉ាងច្រើនរបស់ខ្លួន ហើយអាចចាត់ចែងសំណុំរឿងថ្មីៗឲ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងមានសណ្តាប់ធ្នាប់។ គួរពិចារណាផងដែរ ពីការបង្កើតសាលាឧទ្ធរណ៍បន្ថែមមួយចំនួន ដែលមានវិសាលភាពគ្របដណ្តប់ខេត្តមួយ ឬច្រើន។ សាលាឧទ្ធរណ៍ នៅរាជធានីភ្នំពេញ គួរមានបន្ទប់សវនាការ និងធនធានច្រើនបន្ថែមទៀត ដើម្បីគាំទ្រដល់សកម្មភាពនានារបស់ខ្លួន។

៧៧. រដ្ឋាភិបាល គួរតែគោរពឯករាជ្យភាពរបស់មេធាវី។ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីក៏គួរតែធ្វើវិសោធនកម្មទៅតាមនោះផងដែរ។

៧៨. គណៈមេធាវីផ្ទាល់ក៏ពុំគួរជ្រៀតជ្រែកក្នុងការងាររបស់មេធាវីនានានោះដែរ។ មេធាវីនានា គួរមានសេរីភាពក្នុងការសម្រេចចិត្តផ្តល់សេវាផ្នែកច្បាប់របស់ពួកគេដល់អ្នកណាម្នាក់។ មានតែលក្ខន្តិកៈមេធាវីទេ ទើបអាចកំណត់ពីលក្ខណៈនៃការផ្តល់សេវាផ្នែកច្បាប់នោះបាន ដើម្បីរក្សាបាននូវបទដ្ឋាននៃក្រមសីលធម៌វិជ្ជាជីវៈ។ ក្រមសីលធម៌មេធាវី គួរធ្វើវិសោធនកម្ម ទៅតាមនោះផងដែរ។

៧៩. គណៈមេធាវី គួរតែគាំពារ និងការពារមេធាវីដែលធ្វើការដើម្បីប្រយោជន៍សាធារណៈ ដែលតួនាទីរបស់មេធាវីទាំងនេះ មានសារសំខាន់ណាស់ ក្នុងការលើកស្ទួយយុត្តិធម៌នៅកម្ពុជា។

៨០. ដៃគូអភិវឌ្ឍន៍អន្តរជាតិនានារបស់កម្ពុជា គួរតែបង្កើនការគាំទ្រខាងហិរញ្ញវត្ថុ ដល់កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងជួយដល់គណៈមេធាវីដើម្បីផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ។

៨១. គួរតែបង្កើនថវិកាឲ្យបានគ្រប់គ្រាន់ដល់វិស័យយុត្តិធម៌។ រាជរដ្ឋាភិបាល គួរតែឧបត្ថម្ភហិរញ្ញវត្ថុដល់ការអប់រំច្បាប់សម្រាប់ប្រជាពលរដ្ឋ ឲ្យកាន់តែច្រើនឡើងថែមទៀត ជាពិសេស ដល់ជនក្រីក្រ និងជនងាយរងគ្រោះ។

៨២. ដំណើរការនៃការទទួលឲ្យចូលរៀននៅសាលាបណ្តុះបណ្តាល ឲ្យក្លាយជាចៅក្រម និងព្រះរាជអាជ្ញា គួរតែមានតម្លាភាព និងប្រកួតប្រជែងជាងនេះ (គួរតែតាមរយៈការប្រលងចូល) ហើយត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់អង្គភាពឯករាជពីខាងក្រៅ ដែលមានសមាសភាព តំណាងនានាមកពីវិស័យតុលាការ គណៈមេធាវី និងមហាវិទ្យាល័យច្បាប់នានានៅកម្ពុជា។ គួរតែមានការផ្តល់អាហារូបករណ៍ សម្រាប់អ្នកដែលមកពីក្រុមទន់ខ្សោយនានា ដោយឈរលើគោលការណ៍ ដើម្បីផ្តល់លទ្ធភាពឲ្យពួកគេ អាចចូលរួមក្នុងវិជ្ជាជីវៈច្បាប់។

៨៣. រដ្ឋាភិបាល គួរពន្លឿនដំណើរការនៃការធ្វើសេចក្តីព្រាង ក្រមរដ្ឋបាល និងក្រមនីតិវិធីរដ្ឋបាល។

៨៤. គួរតែផ្តល់ការអប់រំ និងបណ្តុះបណ្តាលផ្នែកច្បាប់ដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលជាអ្នកដើរតួយ៉ាងសំខាន់ ក្នុងដំណើរការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ។

៨៥. រដ្ឋាភិបាល គួរធានាថា គ្រប់បុគ្គលទាំងអស់ដែលត្រូវបានឃាត់ខ្លួន និងឃុំខ្លួន ត្រូវមានអ្នកតំណាងផ្នែកច្បាប់ត្រឹមត្រូវ និងទទួលបានមេធាវីយ៉ាងឆាប់រហ័សបំផុត។ គួរធ្វើវិសោធនកម្មក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីធានាថា បុគ្គលដែលត្រូវបានចោទប្រកាន់ពីការប្រព្រឹត្តបទល្មើសណាមួយ គួរមានវត្តមានរបស់អ្នកតំណាងផ្នែកច្បាប់នៅជាមួយ ក្នុងកំឡុងពេលនៃការសាកសួររបស់នគរបាល។

៨៦. កម្ពុជាគួរផ្តល់ការការពារពិសេសដល់ក្រុមមនុស្សដែលស្ថិតក្នុងក្រុមពិសេសណាមួយ ដូចជា ប្រព័ន្ធយុត្តិធម៌អនីតិជនដាច់ដោយឡែកមួយ ហើយគួរបង្កើតឲ្យមានតុលាការគ្រួសារផងដែរ។

៨៧. រដ្ឋាភិបាល គួរមានគោលនយោបាយល្អ និងច្បាស់លាស់ជាងនេះ និងមានយន្តការរឹងមាំ រួចជាស្រេចមួយ ដើម្បីជួយដល់ប្រព័ន្ធតុលាការ។ គោលនយោបាយបែបនេះ គួរត្រូវបង្កើតឡើង ដើម្បី បញ្ចៀសការបំពេញតួនាទីទ្វេរបស់ស្ថាប័នរដ្ឋាភិបាលនានា នៅក្នុងបញ្ហានេះ។ សម្រាប់កិច្ចការនេះ តួនាទីរបស់ក្រសួងយុត្តិធម៌ គួរត្រូវបានពង្រឹង ហើយក្រសួងនេះគួរទទួលបានធនធានកាន់តែច្រើនឡើង នៅក្នុងកិច្ចការជួយដល់ប្រព័ន្ធតុលាការ។ ស្ថាប័នរដ្ឋាភិបាលនានា ឬបណ្តារដ្ឋមន្ត្រី ពុំគួរមានតួនាទីណា មួយ នៅក្នុងការគ្រប់គ្រង និងមានឥទ្ធិពលលើការងាររបស់តុលាការនោះទេ។

៨៨. ក្រឡាបញ្ជី និងមន្ត្រីតុលាការផ្សេងៗ គួរស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីតុលាការ សាមី ជាជាងស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌។

៨៩. គួរផ្តល់ការបណ្តុះបណ្តាលត្រឹមត្រូវ នៅក្នុងវិទ្យាសាស្ត្រកោសល្យវិច្ច័យ សម្រាប់មន្ត្រី នគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរនានា។

៩០. គួរមានការផ្តល់ជំនួយផ្នែកច្បាប់ពីសំណាក់រដ្ឋ ដល់ជនក្រីក្របំផុត និងបុគ្គលផ្សេងទៀត ដែលស្ថិតក្នុងក្រុមមនុស្សងាយរងគ្រោះ និងក្រុមដែលត្រូវគេផាត់ចេញពីសង្គម។

៩១. ទស្សនៈស្តីពីតុលាការគំរូ គួរត្រូវបានពង្រីកឲ្យទូលំទូលាយឡើង ហើយតុលាការទាំង នោះ គួរត្រូវបានផ្តល់ឲ្យ នូវធនធានកាន់តែច្រើនឡើង ដើម្បីផ្តល់លទ្ធភាពឲ្យពួកគេ ដំណើរការជា តុលាការគំរូដ៏ពិតប្រាកដ។

៩២. តុលាការនីមួយៗ គួរមានអ្នកកាន់បញ្ជីរៀងខ្លួន ព្រមទាំងមានប្រព័ន្ធរក្សាសំណុំរឿង និងសំណុំលិខិតបានត្រឹមត្រូវ។ ចៅក្រម ពុំគួររក្សាទុកសំណុំរឿងក្តីនៅជាមួយខ្លួននោះទេ ហើយក៏ពុំគួរ នាំសំណុំរឿងទាំងនោះទៅជាមួយ នៅពេលផ្លាស់ប្តូរទៅតុលាការផ្សេងនោះដែរ។

៩៣. តុលាការនានា គួរប្រកាន់យកគោលនយោបាយដែលកាន់តែមានតម្លាភាពឡើង ក្នុងការ បញ្ចេញច្បាប់ចម្លងនៃសាលក្រមនានា និងឯកសារតុលាការផ្សេងៗទៀត ទៅដល់ភាគីពាក់ព័ន្ធនានា។

៩៤. រដ្ឋាភិបាល និងស្ថាប័នរដ្ឋផ្សេងៗ គួរទទួលស្គាល់ពីសារសំខាន់នៃការអនុវត្តន៍តាម ការ បែងចែកការងារ រវាងគណៈកម្មាធិការសុរិយោដី និងតុលាការនានា អនុលោមតាមបទប្បញ្ញត្តិក្នុង មាត្រា៤៧ នៃច្បាប់ភូមិបាល ឆ្នាំ២០០១។

**តុលាការ និងសេរីភាពនៃការបញ្ចេញមតិ**

*៩៥. រដ្ឋាភិបាលគួរពិនិត្យក្រមព្រហ្មទណ្ឌថ្មីឡើងវិញដើម្បីធានាថា ក្រមនេះពិតជាអនុលោមតាមកំរិតនៃការរឹតត្បិតដែលអាចអនុញ្ញាតឲ្យធ្វើបាន លើសេរីភាពនៃការបញ្ចេញមតិ ដូចដែលបានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ឆ្នាំ១៩៦៦ (ICCPR)។*

*៩៦. តុលាការ គួរអនុវត្តច្បាប់សារព័ត៌មាន ចំពោះបញ្ហាដែលទាក់ទិននឹងអ្នកសារព័ត៌មាន ព្រមទាំងអនុញ្ញាតឲ្យមានការដកអត្ថបទចេញ ការកែតម្រូវ និងសិទ្ធិនៃការឆ្លើយតប មុនពេលឈានទៅដល់ការដាក់បណ្តឹងប្រឆាំងនឹងអ្នកសារព័ត៌មាននានា ចំពោះការបោះផ្សាយព័ត៌មាន ដែលត្រូវបានចាត់ទុកថាមិនត្រឹមត្រូវ ឬប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលនានា ឬសូម្បីតែការគម្រាមកំហែងដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ។ នីតិវិធីផ្លូវច្បាប់នៅក្នុងករណីទាំងនេះ គួរតែជាបណ្តឹងរដ្ឋ-ប្បវេណី ហើយមិនមែនជាបណ្តឹងអាជ្ញានោះទេ។*

*៩៧. បុគ្គលសាធារណៈនានា គួរត្រៀមខ្លួនអត់ទ្រាំនឹងការរិះគន់ ហើយជៀសវាងប្រើប្រាស់តុលាការ ដើម្បីបំបិទការរិះគន់ ព្រោះការរិះគន់ជាផ្នែកមួយ ជួយធ្វើឲ្យលទ្ធិប្រជាធិបតេយ្យ ដំណើរការបានដោយរលូន។ ជាការប្រសើរជាង ដែលយកសេចក្តីពិត ទៅតបតនឹងសេចក្តីមិនពិត ជាជាងប្រើប្រាស់ការបំភិតបំភ័យតាមផ្លូវតុលាការ។ ស្ថាប័នរដ្ឋាភិបាលនានា គួរតែរៀបចំឲ្យមានអ្នកនាំពាក្យរៀងខ្លួន ដើម្បីប្រឆាំងទៅនឹងការរិះគន់នានាលើគោលនយោបាយរបស់រដ្ឋាភិបាល ឬប្រតិកម្មចំពោះអត្ថបទសារព័ត៌មានណាមួយ ដែលមានលក្ខណៈរសើបចំពោះបុគ្គលនៅក្នុងតំណែងសាធារណៈនានា ជាជាងជ្រើសរើសផ្លូវ ទៅប្រើបណ្តឹងអាជ្ញានោះ។*

*៩៨. បទបរិហាកេរ្តិ៍ និងបទផ្សាយព័ត៌មានមិនពិត គួរតែដកចេញពីបទល្មើសព្រហ្មទណ្ឌទាំងស្រុង។ សេចក្តីថ្លែងការណ៍ដែលត្រូវបានចាត់ទុកថា ជាការគម្រាមកំហែងដល់សន្តិសុខជាតិ ត្រូវតែទទួលបានការបកស្រាយ ឲ្យស្របតាមកាតព្វកិច្ចនានា ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់កម្ពុជា។*

*៩៩. ទស្សនទាននៃ "ការគម្រាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ" គួរត្រូវបានផ្តល់និយមន័យ ដោយច្បាប់ និងតុលាការនានា នៅក្នុងអត្ថន័យដ៏ចង្អៀតបំផុត តាមដែលអាចធ្វើទៅបាន ដើម្បីលើកកំពស់ដល់សេរីភាពនៃការបញ្ចេញមតិ។ នៅក្នុងសេចក្តីសម្រេចចិត្តរបស់ខ្លួន ចៅក្រមនានា គួរបង្ហាញនៅក្នុងវាក្យស័ព្ទជាក់លាក់នានា ថាតើសេចក្តីថ្លែងការណ៍ ឬការបញ្ចេញមតិដោយផ្នែកណា*

*មួយ បាន ឬនឹងគម្រាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ តាមរបៀបណា។ តុលាការ ពុំគួរយកការពោលអះអាងណាមួយ ដែលត្រូវបានធ្វើឡើងដោយអរូបី មកពិចារណានោះទេ។*

*១០០. ចៅក្រម និងព្រះរាជអាជ្ញានានា គួរទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ អំពីច្បាប់សិទ្ធិមនុស្ស និងអំពីការបកស្រាយច្បាប់ជាតិនានា ដោយអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលមានចែងក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ដែលកម្ពុជាជារដ្ឋភាគី។*

*១០១. គួរតែមានច្បាប់ស្តីពីសេរីភាពទទួលបានព័ត៌មាននៅកម្ពុជា ដើម្បីផ្តល់លទ្ធភាពឲ្យអ្នកសារព័ត៌មាន និងសាធារណជន ទទួលបានព័ត៌មានស្តីពីបញ្ហានៃប្រយោជន៍សាធារណៈ។ ច្បាប់បែបនេះក៏នឹងលើកកំពស់ដល់វិជ្ជាជីវៈសារព័ត៌មាន ឲ្យប្រកបដោយការទទួលខុសត្រូវ តម្លាភាព និងគណនីភាពផងដែរ។*

**តារាងពេលវេលាដើម្បីអនុវត្តអនុសាសន៍ទាំងនេះ**

*១០២. អ្នករាយការណ៍ពិសេស លើកទឹកចិត្តរាជរដ្ឋាភិបាលកម្ពុជា ឲ្យបង្កើតកម្មវិធីសកម្មភាពមួយ ដោយមានតារាងពេលវេលាជាក់លាក់ ដើម្បីអនុវត្តអនុសាសន៍ទាំងនេះ៕*

ឲឲឲ*ៜៜៜ